ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរ
ជាតិនៃប្រទេសជប៉ុន

# របាយការណ៍
# ស្តីពី
# ការអង្កេតតម្លៃផលិតផល និងធាតុចូលកសិកម្មនៅ
# ព្រំដែនកម្ពុជា-វៀតណាម

រៀបចំដោយៈ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

គាំទ្រដោយៈ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

ខែកញ្ញា ឆ្នាំ២០១៥

**របាយការណ៍ស្តីពីការអង្កេតតម្លៃផលិតផល និងធាតុចូលកសិកម្មនៅព្រំដែនកម្ពុជា-វៀតណាម**
បោះពុម្ពផ្សាយ៖ ខែកញ្ញា ឆ្នាំ២០១៥

បោះពុម្ពដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម (MAFF)

គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

អស័យដ្ឋាន៖ # ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ៖ (០២៣) ៨៨៣ ៤២៧ ទូរសារ៖ (០២៣) ៨៨៣ ៤២៧

© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន
(JICA)
គម្រោង BPAC

សាកលវិទ្យាល័យអានយ៉ាង
បណ្ឌិត ហៃ ត្រាន

# របាយការណ៍
# ស្តីពីការអង្កេតតម្លៃផលិតផលនិងធាតុចូលកសិកម្មនៅព្រំដែនកម្ពុជា-វៀតណាម

## ១. សាវតា និងគម្រោងស្រាវជ្រាវ

### ១.១ សាវតា

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានផ្តល់ជំនួយដល់ប្រទេសកម្ពុជាដើម្បីដំណើរការគម្រោងដែលមានឈ្មោះថា"គម្រោងបង្កើតសហគមន៍កសិកម្មគំរូតម្រង់ទិសដៅទៅលើការធ្វើជំនួញ" (BPAC) សម្រាប់រយៈពេលប្រាំឆ្នាំ។ អង្គភាពអនុវត្តគម្រោង BPAC នេះមាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម (DACP) នៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)។ គម្រោង BPAC និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឯកភាពជ្រើសរើសយកខេត្តតាកែវ កំពង់ចាម ស្វាយរៀង និងកំពង់ស្ពឺ ជាខេត្តគោលដៅ។

គម្រោង BPAC មានគោលបំណងបង្កើតសហគមន៍កសិកម្មគំរូតម្រង់ទិសដៅទៅលើការធ្វើជំនួញនៅក្នុងខេត្តគោលដៅ។ ដូច្នេះ គម្រោង BPAC ចង់ធ្វើការអង្កេតតម្លៃផលិតផលនិងធាតុចូលកសិកម្មនៅក្នុងបណ្តាញទីផ្សាររវាងប្រទេសវៀតណាមនិងប្រទេសកម្ពុជា។ គោលបំណងនៃការអង្កេតនេះគឺគម្រោង BPAC នឹងផ្តល់ព័ត៌មានទីផ្សារដល់សហគមន៍កសិកម្មនៅក្នុងខេត្តគោលដៅ ហើយសហគមន៍អាចចាប់ផ្តើមធ្វើអាជីវកម្មទៅតាមគោលបំណងរបស់គម្រោង។

ប្រទេសវៀតណាម និងកម្ពុជាគឺជាប្រទេសជិតខាងគ្នាដែលមានព្រំប្រទល់រួមគ្នាប្រវែង ១.០០០គីឡូម៉ែត្រ (គ.ម)។ ប្រទេសកម្ពុជាមានខេត្តចំនួន ៩ ដែលមានព្រំប្រទល់ជាប់នឹងខេត្តចំនួន ១០ របស់ប្រទេសវៀតណាម។ ប្រទេសទាំងពីរមានច្រកព្រំដែនអន្តរជាតិ ចំនួន ១០ ច្រកព្រំដែនជាតិចំនួន១២ ច្រកព្រំដែនបន្ទាប់បន្សំចំនួន ២៥ និងផ្លូវលំចំនួន ១០០ ដែលជាលក្ខខណ្ឌដ៏ល្អដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្មទ្វេភាគី។

ការនាំចេញដ៏ចម្បងរបស់កម្ពុជាទៅកាន់ប្រទេសវៀតណាមគឺផលិតផលកសិកម្មដែលមាន ដូចជា ស្រូវ ស្វាយ បន្លែ ត្រី ដំឡូងមី ស្វាយចន្ទី និងផលិតផលធ្វើអំពីឈើជាដើម រីឯការនាំចូលពីប្រទេសវៀតណាមវិញភាគច្រើនជាធាតុចូលកសិកម្មដូចជា ជី ថ្នាំកម្ចាត់សត្វល្អិត ឧបករណ៍កសិកម្ម ទំនិញប្រើប្រាស់ប្រចាំថ្ងៃ ផ្លែឈើ បន្លែ និងផលិតផលផ្សេងៗទៀត ដូចជា ថ្នាំគីមី ផលិតផលជ័រនិងផលិតផលឧស្សាហកម្មផ្សេងៗ។

ទោះជាយ៉ាងណាក៏ដោយ កសិករនៅក្នុងប្រទេសកម្ពុជាជាច្រើនខ្វះខាតព័ត៌មានទីផ្សារពីប្រទេសវៀតណាម ដូចជា តម្លៃ ទីតាំងចែកចាយទំនិញ ការកែច្នៃ និងអ្នកទិញចុងក្រោយ។ កសិករកម្ពុជាពឹងផ្អែកលើព័ត៌មានដែលទទួលបានពីឈ្មួញកណ្ដាលនៅប្រទេសកម្ពុជា ដូច្នេះហើយ ពួកគាត់មិនអាចចរចាជាមួយឈ្មួញកណ្ដាលបានទេ។ បញ្ហានេះបានកាត់បន្ថយប្រាក់ចំណេញរបស់កសិករកម្ពុជានៅពេលពួកគាត់លក់ផលិតផលកសិកម្មទៅឱ្យប្រទេសវៀតណាម និងនាំចូលទំនិញនិងធាតុចូលកសិកម្មពីប្រទេសវៀតណាមមកវិញ។

គម្រោងបង្កើតសហគមន៍កសិកម្មគំរូតម្រង់ទិសដៅទៅលើការធ្វើជំនួញនេះ (BPAC) សំដៅពង្រឹងសមត្ថភាពរបស់សហគមន៍កសិកម្ម (AC) ដែលជាក្រុមកសិករទ្រង់ទ្រាយតូចៗដើម្បីឱ្យគាត់មានការយល់ដឹងអំពីទីផ្សារនិងការធ្វើជំនួញ។ គោលបំណងរបស់គម្រោងគឺដើម្បីផ្ដល់ព័ត៌មានទីផ្សារទាក់ទងនឹងស្រូវ ទំនិញប្រើប្រាស់ ផលិតផល និងធាតុចូលកសិកម្ម ដល់សហគមន៍កសិកម្ម និងសមាជិកសហគមន៍កសិកម្ម ។ បន្ទាប់មក សហគមន៍កសិកម្មអាចបង្កើតជាសេវាកម្មមួយចំនួនដូចជាទីផ្សាររួមគ្នា អាជីវកម្មទិញទំនិញរួមគ្នាក្នុងចំណោមសមាជិករបស់ខ្លួន ហើយសហគមន៍កសិកម្មក៏អាចចូលរួមនៅក្នុងសង្វាក់ទីផ្សារនៃការនាំចូល ឬការនាំចេញផលិតផលកសិកម្មរវាងប្រទេសវៀតណាមនិងកម្ពុជាផងដែរ។

## ១.២ គម្មវត្ថុនៃការស្រាវជ្រាវ

- អង្កេតតម្លៃស្រូវ ផលិតផលនិងធាតុចូលកសិកម្មសំខាន់ៗដែលនាំចេញនិងនាំចូលនៅច្រកព្រំដែនកម្ពុជា-វៀតណាម។
- ស្វែងយល់អំពីលក្ខណៈនិងព័ត៌មានទីផ្សារពាក់ព័ន្ធនឹងការនាំចេញ នាំចូលស្រូវ និងផលិតផលនិងធាតុចូលកសិកម្មសំខាន់ៗនៅច្រកព្រំដែនកម្ពុជា-វៀតណាម។

## ១.៣ តំបន់ស្រាវជ្រាវ

យើងបានធ្វើតេស្តសាកល្បងមុនពេលចុះអង្កេតនៅតាមច្រកព្រំដែនកម្ពុជា-វៀតណាម ដែលរួមមានខេត្តកំពត តាកែវ កណ្ដាល ព្រៃវែង និងស្វាយរៀង នៃប្រទេសកម្ពុជា និងខេត្តគៀនយ៉ាង ខេត្តអានយ៉ាង ខេត្តដុងថាប់ និងខេត្តឡុងអាន នៃប្រទេសវៀតណាម។

បន្ទាប់មក យើងបានជ្រើសរើសយកខេត្តដែលត្រូវចុះធ្វើការអង្កេតនៅតាមព្រំដែនខេត្តតាកែវ និងខេត្តស្វាយរៀង (កម្ពុជា) ខេត្តអានយ៉ាង និងឡុងអាន (វៀតណាម) ដោយសារពេលវេលា និងថវិកាមានកម្រិត។

ផែនទី កម្ពុជាក្រោម សណ្ដានទន្លេមេគង្គ ឬអតីតកូសាំងស៊ីនបារាំង

**Map of Mekong Delta Region Provinces, Vietnam**




Map: 2008 Human Rights Watch

France transfers the territories of the Kingdom of Cambodia, Kampuchea Krom, to Emperor Bao Dai of Vietnam on June 4, 1949.

តារាង១៖ បង្ហាញអំពីឈ្មោះច្រកព្រំដែនកម្ពុជា-វៀតណាមដែលជាកន្លែងចុះអង្កេតប្រមូលទិន្នន័យ។

តារាង១៖ ច្រកព្រំដែនដែលបានចុះអង្កេត

| # | ឈ្មោះច្រកព្រំដែន | | កម្រិតនៃច្រកព្រំដែន (*) | ផ្លូវគោក ឬ ផ្លូវទឹក | ឈ្មោះស្រុក | | ឈ្មោះខេត្ត | |
|---|---|---|---|---|---|---|---|---|
| | វៀតណាម | កម្ពុជា | | | វៀតណាម | កម្ពុជា | វៀតណាម | កម្ពុជា |
| ១ | ទីញបៀន | ភ្នំដិន | ១ | ផ្លូវគោក | ទីញបៀន | គិរីវង់ | អានយ៉ាង | តាកែវ |
| ២ | ដូងស៊ូ ២១, ភូមិអានណង់ | តារុន ភូមិ ថាមឌុង | ៣ | ផ្លូវគោក | ទីញបៀន | គិរីវង់ | អានយ៉ាង | តាកែវ |
| ៣ | វិញ គៀ | | ៣ | ផ្លូវគោក | ទ្រីតុន | | អានយ៉ាង | តាកែវ |
| ៤ | សុងត្រាង | ស្វាយអង្គុង | ២ | ផ្លូវគោក | តានហ៊ុង | កំពង់ត្របែក | ឡុងអាន | ស្វាយរៀង |
| ៥ | បេនផូ | ភូមិគ្រួ | ៣ | ផ្លូវគោក | តានហ៊ុង | ស្វាយជ្រំ | ឡុងអាន | ស្វាយរៀង |
| ៦ | ឡុងខុត | សំរ៉ោណង | ៣ | ផ្លូវគោក | តានហ៊ុង | ស្វាយជ្រំ | ឡុងអាន | ស្វាយរៀង |
| ៧ | ប៊ីញហៀប | ព្រៃវល្លិ | ១ | ផ្លូវគោក | ម៉ុកហូ | កំពង់រោទិ៍ | ឡុងអាន | ស្វាយរៀង |

(*) ១៖ ច្រកព្រំដែនអន្តរជាតិ

២៖ ច្រកព្រំដែនសំខាន់ៗ (ច្រកព្រំដែនខេត្ត)

៣៖ ច្រកព្រំដែនបន្ទាប់បន្សំ

## ២. លទ្ធផលនៃការស្រាវជ្រាវ

### ២.១ ផលិតផលកសិកម្មរបស់ប្រទេសកម្ពុជាដែលបាននាំចេញទៅប្រទេសវៀតណាម

#### ២.១.១ ស្រូវ

- ស្រូវ គឺជាផលិតផលដ៏សំខាន់ដែលបាននាំចេញទៅប្រទេសវៀតណាមច្រើនជាងគេ។
- ស្រូវស្រាល (ប្រភេទ IR504) ត្រូវបានដាំដុះនៅតាមបណ្តាខេត្តនានា ដូចជាខេត្តកំពត តាកែវ កណ្តាល ព្រៃវែង ស្វាយរៀង កំពង់ចាម និងខេត្តកំពង់ស្ពឺ។ ខេត្តតាកែវទទួលបានទិន្នផលស្រូវច្រើនជាងគេ ដោយសារតែខេត្តនេះបង្កបង្កើនផលស្រូវស្រាល (ប្រភេទ IR504) និងធ្វើស្រែចាប់ពី២ ទៅ ៣ដងក្នុងមួយឆ្នាំ។ ភាគច្រើននៃស្រូវស្រាលដែលបាននាំចូលពីប្រទេសកម្ពុជាត្រូវបានយកទៅកែច្នៃដើម្បីធ្វើការនាំចេញ។
- ស្រូវធ្ងន់ (ម្លិះ ឬ Soc) បានដាំដុះនៅតំបន់ខ្ពង់រាបឆ្ងាយពីព្រំប្រទល់ប្រទេសវៀតណាម ដូចជាខេត្តកំពង់ស្ពឺ ពោធិ៍សាត់ កំពង់ឆ្នាំង បាត់ដំបង សៀមរាប កំពង់ចាម និងខេត្តមួយចំនួនទៀតជាប់ព្រំដែនប្រទេសឡាវ ដូចជាខេត្តស្ទឹងត្រែងជាដើម។

ស្រូវធ្ងន់ដែលបាននាំចូលពីប្រទេសកម្ពុជាភាគច្រើនគឺសម្រាប់អតិថិជនក្នុងប្រទេសវៀតណាម។ តម្រូវការប្រើប្រាស់ស្រូវម្លិះ ឬ Soc នៅប្រទេសវៀតណាមកំពុងមានកើនឡើង។ អតិថិជនកម្រិតខ្ពស់និងកម្រិតមធ្យមនៅប្រទេសវៀតណាមចូលចិត្តបរិភោគអង្ករម្លិះ និងអង្ក Soc ពីព្រោះគុណភាពរបស់វាល្អជាងអង្ករវៀតណាម ហើយអតិថិជនវៀតណាមយល់ថាស្រូវធ្ងន់ត្រូវបានដាំដុះតាមលក្ខណៈធម្មជាតិ ឬវាជាអង្ករសរីរាង្គដែលកសិករប្រើប្រាស់ជីនិងថ្នាំកម្ចាត់សត្វល្អិតតិចបំផុត[1]។ ប្រទេសវៀតណាមធ្លាប់ដាំដុះស្រូវធ្ងន់នៅមុនឆ្នាំ ១៩៩០ ហើយប្រជាជនវៀតណាមជាច្រើនទទួលស្គាល់គុណភាពរបស់ស្រូវធ្ងន់នេះ។

---

[1] ការសិក្សានេះបានសម្ភាសលោក Danh LDong នៅខេត្តស្ទឹងត្រែង។ លោកដាំដុះស្រូវធ្ងន់ប្រភេទផ្កាម្លិះលើផ្ទៃដីទំហំ ៣,៥ ហិចតា ក្នុងឆ្នាំ២០១៤ គាត់បានប្រើជី NPK បីបាវ ទំងន់ ១៥០គីឡូក្រាម និងមិនបានប្រើថ្នាំកម្ចាត់សត្វល្អិតទេសម្រាប់ផ្ទៃដី ៣,៥ហិកតានេះ។ មានន័យថា គាត់ប្រើប្រាស់ជីចំនួន ៥ គីឡូក្រាមក្នុងផ្ទៃដីដាំដំណាំ ១.០០០ម$^{២}$។

បើតាមការការស្ទង់មតិអ្នកលក់ដុំ/ឈ្មួញកណ្តាលបានឲ្យដឹងថា បរិមាណស្រូវ IR504 ដែលបាននាំចេញទៅប្រទេសវៀតណាមមានការធ្លាក់ចុះជាលំដាប់ ដោយសារទីផ្សារនាំចេញអង្ករគុណភាពអន់នៅក្នុងប្រទេសវៀតណាមកំពុងមានការធ្លាក់ចុះ។ លើសពីនេះ រដ្ឋាភិបាលកម្ពុជាបានវិនិយោគតំបន់ឧស្សាហកម្មកែច្នៃអង្ករជាច្រើនតំបន់ក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០១៣ មក ហើយរោងចក្រកែច្នៃមួយចំនួនបានចាប់ផ្តើមដំណើរការចាប់ពីឆ្នាំ ២០១៣។

## ២.១.២ ផ្លែស្វាយ

ផ្លែស្វាយកម្ពុជា ឬផ្លែស្វាយខ្ចី ដែលប្រជាជនវៀតណាមហៅថា "xoai keo" ត្រូវបាននាំចេញទៅប្រទេសវៀតណាមយ៉ាងច្រើនដើម្បីបំពេញតម្រូវការបរិភោគផ្លែស្វាយនៅក្នុងប្រទេសវៀតណាមពីព្រោះប្រភេទស្វាយខ្ចីនៅប្រទេសកម្ពុជាមានគុណភាពល្អជាងផ្លែស្វាយនៅប្រទេសវៀតណាម។


រូបភាពទី១៖ ផ្លែស្វាយខ្ចីកម្ពុជា - Xoai Keo

ការសិក្សានេះបានឲ្យដឹងថា ផ្លែស្វាយរបស់កម្ពុជាដែលនាំចេញទៅប្រទេសវៀតណាមមិនមែនសម្រាប់តែអតិថិជននៅតំបន់ដីសណ្តទន្លេមេគង្គ និងទីក្រុងហូជីមិញប៉ុណ្ណោះទេ ថែមទាំងសម្រាប់អតិថិជននៅទីក្រុងហាណូយផងដែរ។

## ២.១.៣ សត្វពាហនៈ (គោ ក្របី)

នៅតាមបណ្តោយព្រំដែនរវាងប្រទេសវៀតណាម និងប្រទេសកម្ពុជាមាន "ទីផ្សារលក់សត្វពាហនៈ" ជាច្រើនកន្លែងដែលបានកើតឡើងដោយឯកឯងនៅតាមព្រំដែនវៀតណាម ប៉ុន្តែទីផ្សារនេះភាគច្រើនគឺមាននៅខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តស្វាយរៀង។

---

លើសពីនេះ លោក LDong ប្រមូលផលស្រូវបានចំនួន ៩,៦តោន។ នេះមានន័យថា ស្រូវផ្កាម្លិះផ្តល់ទិន្នផល ២,៧៥ តោន/ហិកតា។ គាត់បានលក់ស្រូវក្នុងតម្លៃ ១.២០០រៀល/គីឡូក្រាម (~៦.០០០ដុង/គ.ក)។

ជាធម្មតា នៅព្រំដែនវៀតណាមប្រជាជនបង្កើតទីផ្សារលក់សត្វពាហនៈ (នៅលើដីទំនេរជិតព្រំដែន ដោយមានរៀបចំ ចំណីនិងទឹកសម្រាប់សត្វគោ ហើយមានមនុស្សម្នាក់ជាអ្នកគ្រប់គ្រង និងបកប្រែ)។ ឈ្មួញកណ្តាលដែលជាអ្នកទិញលក់គោក្របីជាច្រើនប្រមូលទិញគោ ក្របីនៅក្នុងប្រទេសកម្ពុជារួចយកទៅលក់នៅទីផ្សារលក់សត្វពាហនៈ នៅតាមបណ្តោយព្រំដែនវៀតណាម ដែលមានទាំងកូនគោ កូនក្របី និងគោ ក្របីជំទង់។



រូបភាពទី២៖ ទីផ្សារគោក្របីរវាងខេត្តតាកែវ-អានយ៉ាង

ទីផ្សារលក់សត្វពាហនៈមានភាពមមាញឹកណាស់ ហើយចំនួនគោក្របីជួញដូរក្នុងមួយថ្ងៃគឺចាប់ពី ២០០ ទៅ ៥០០ក្បាល។ សព្វថ្ងៃនេះ មានតម្រូវការទិញកូនគោនិងគោជំទង់ជាច្រើនក្បាលនៅក្នុងប្រទេសវៀតណាមពីព្រោះតម្រូវការសាច់គោក្នុងប្រទេសវៀតណាមមានការកើនឡើងយ៉ាងឆាប់រហ័ស ហើយកសិករវៀតណាមទទួលបានជោគជ័យក្នុងការទិញកូនគោពីប្រទេសកម្ពុជាដើម្បីចិញ្ចឹមយកសាច់។

## ២.១.៤ ផលិតផលកសិកម្មរបស់ប្រទេសថៃ

ផលិតផលកសិកម្មរបស់ប្រទេសថៃមួយចំនួនត្រូវបានឆ្លងកាត់តាមប្រទេសកម្ពុជាមុនពេលនាំចេញទៅប្រទេសវៀតណាម ក្នុងនោះរួមមាន អំពិលថៃ ធុរេន មង្ឃុត ឡុងកុង ខ្ញី និងអង្ករដំណើប។

លទ្ធផលនៃការអង្កេតនេះរកឃើញថាទិន្នផលអង្ករដំណើបថៃដែលបាននាំចេញទៅប្រទេសវៀតណាមមានការធ្លាក់ចុះ ផ្ទុយទៅវិញ អង្ករដំណើបដែលផលិតនៅប្រទេសវៀតណាម (ខេត្តអានយ៉ាង និង ខេត្តឡុងអាន) ត្រូវបានដឹកជញ្ជូនទៅតំបន់ព្រំដែន បន្ទាប់មក ប្រជាជនច្រកអង្ករដំណើបនោះក្នុងបាវដែលមានស្លាកសញ្ញាថៃរួចលក់ទៅប្រទេសវៀតណាមវិញ។

### ២.១.៥ ផលិតផលកសិកម្មតាមរដូវកាលរបស់កម្ពុជានាំចេញទៅវៀតណាម

ការស្រាវជ្រាវបានឲ្យដឹងថា ផលិតផលកសិកម្មរបស់ប្រទេសកម្ពុជាមួយចំនួនបានលក់ទៅប្រទេសវៀតណាមទៅតាមរដូវកាលមានដូចជា៖ សណ្តែកស សណ្តែកក្រហម និងសត្វប្រមាញ់តាមធម្មជាតិដូចជា កណ្តុរស្រែ ខ្យង និងត្រីជាដើម។

ឈ្មួញកម្ពុជាលក់កណ្តុរស្រែទៅប្រទេសវៀតណាមជាច្រើនក្បាលក្នុងមួយថ្ងៃៗ ចាប់ពីខែវិច្ឆិកា ដល់ខែសីហា។ ផ្ទុយទៅវិញ ឈ្មួញកម្ពុជាលក់ត្រីធម្មជាតិទៅប្រទេសវៀតណាមនៅរដូវទឹកឡើងនៅកម្ពុជា ចាប់ពីខែសីហា ដល់ខែវិច្ឆិកា ហើយទិញត្រីជាច្រើនប្រភេទពីប្រទេសវៀតណាមមកវិញ ចាប់ពីខែធ្នូ ដល់ខែកក្កដា។

## ២.២ ផលិតផលកសិកម្ម និងទំនិញវៀតណាមដែលនាំចេញទៅប្រទេសកម្ពុជា

### ២.២.១ បន្លែសម្រាប់បរិភោគប្រចាំថ្ងៃ


រូបភាពទី៣៖ បន្លែពីដុងថាប់ (វៀតណាម) លក់ទៅខេត្តស្វាយរៀង

បន្លែជាច្រើនប្រភេទដែលបានដាំដុះនៅក្នុងប្រទេសវៀតណាម ត្រូវបានលក់ទៅឲ្យប្រទេសកម្ពុជាជារៀងរាល់ថ្ងៃក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ បន្លែទាំងនោះរួមមាន ត្រសក់ ឪឡឹក ប៉េងប៉ោះ ម្នាស់ ស្ពៃក្តោប ម្ទេស ល្ពៅ ស៊ូ រំដេង ការ៉ុត ត្រឡាច ម្រះ ឃ្លោក ស្ពៀតពោត ខ្ទឹមស ខ្ទឹមក្រហម ស្ពៃតឿ ត្រប់វែង ត្រប់ខ្លី។ល។ ក្នុងចំណោមបន្លែទាំងនោះ ៥០% ជា ត្រសក់ ឪឡឹក ស្ពៃក្តោប ត្រឡាច ល្ពៅ និងម្ទេស។ ក្រៅពីច្រកព្រំដែនដែលបានធ្វើការអង្កេត បន្លែវៀតណាមត្រូវបានលក់ទៅកន្លែងជាច្រើនទៀតនៅតាមព្រំដែនប្រទេសកម្ពុជា ហើយជនជាតិវៀតណាមជាច្រើនដែលជាអ្នកលក់ដូរតាមដងផ្លូវរាល់ថ្ងៃបានលក់បន្លែទាំងនេះទៅឱ្យប្រទេសកម្ពុជា។ ក្នុងចំណោមទីតាំងខាងលើនេះ ច្រកព្រំដែនចំនួនពីរដែលមានចំនួនប្រជាជនច្រើនបំផុតគឺច្រកទីញបៀន (ខេត្តអានយ៉ាង) - ភ្នំពេញ (តាកែវ) និង ប៊ីញហៀប (ឡុងអាន) – ព្រៃវល្លិ (ស្វាយរៀង)។

ក្រៅពីបន្លែដែលបានដាំដុះនៅក្នុងខេត្តអានយ៉ាង កាន់ថូ វិញឡុង ដុងថាប់ និងឡុងអាន ការអង្កេតរកឃើញប្រភេទបន្លែមួយចំនួនទៀតដែលបានដាំដុះនៅដាឡាត់ខេត្តឡាំដុងតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាមដែលមានចម្ងាយ ២៨០គីឡូម៉ែត្រ ភាគខាងលិចនៃទីក្រុងហូជីមិញ ដូចជា ការ៉ុត ដំឡូងបារាំង ប៉េងប៉ោះ និងផ្កាខាត់ណា។ ជាពិសេស ការសិក្សានេះបានរកឃើញថា ផ្លែឈើ និងបន្លែចិនមួយចំនួន រួមមាន ផ្លែឈើសរីរាង្គ ផ្លែប៉ោម ទំពាំងបាយជូរ ការ៉ុត និងដំឡូង ត្រូវបានលក់ឲ្យប្រទេសកម្ពុជា។

អាស្រ័យទៅតាមរដូវកាល ឈ្មួញកម្ពុជាទិញផ្លែឈើនិងបន្លែជាច្រើនប្រភេទពីប្រទេសវៀតណាមសម្រាប់បរិភោគប្រចាំថ្ងៃ។

## ២.២.២ ផ្លែឈើត្រូពិក

ផ្លែឈើមួយចំនួនដែលដាំដុះនៅប្រទេសវៀតណាមបានលក់ទៅប្រទេសកម្ពុជាទៅតាមរដូវកាល ដូចជា សាវម៉ាវ មៀន ស្វាយកែវរមៀត ស្រកានាគ ត្រួលែនក្រូចឃ្វិច។ល។

លទ្ធផលនៃការអង្កេតនេះក៏បានបង្ហាញផងដែរថាផ្លែឈើជាច្រើនដែលនាំចូលពីប្រទេសចិនត្រូវបានឈ្មួញចិនច្រកជាកញ្ចប់បិតស្លាកវៀតណាម ហើយលក់ទៅប្រទេសកម្ពុជាដែលក្នុងនោះរួមមាន ក្រូច គីវី ទំពាំងបាយជូរ ផ្លែប៉ោម និងផ្លែឈើសិរីរាង្គតូចៗដូចជា ក្រូចជប៉ុនជាដើម។ បច្ចុប្បន្ននេះ ផ្លែឈើចិនពិបាកលក់នៅក្នុងទីផ្សារនៃប្រទេសវៀតណាមណាស់ពីព្រោះធ្លាប់មានការប្រើសារធាតុពុលនៅក្នុងផ្លែឈើចិនជាច្រើនករណីត្រូវបានកត់ត្រាចាប់តាំងពីឆ្នាំ ២០១០ មកម្ល៉េះ ហើយអ្នកប្រើប្រាស់ជនជាតិវៀតណាមបានកាត់បន្ថយការបរិភោគផ្លែឈើចិន។ ផ្ទុយទៅវិញផ្លែឈើទាំងនោះមានចរាចរច្រើននៅក្នុងប្រទេសកម្ពុជា ពីព្រោះវាមានតម្លៃថោកជាងផ្លែឈើដែលដាំដុះនៅក្នុងប្រទេសវៀតណាមរហូតដល់ ៣០% ទៅ ៤០%។

## ២.២.៣ ធាតុចូលកសិកម្ម និងចំណីសត្វពាហនៈសម្រាប់ផលិតកម្មកសិកម្ម

ការសិក្សានេះបង្ហាញថា កសិករខ្មែរជាច្រើននៅតាមបណ្តោយព្រំដែនទិញជី ថ្នាំកម្ចាត់សត្វល្អិត ឧបករណ៍កសិកម្ម ប្រេងម៉ាស៊ូត និងប្រេងសាំង[2]ពីប្រទេសវៀតណាម។ មានវិធីពីរដែលកសិករខ្មែរអាចទិញជី និងថ្នាំគីមីសម្រាប់ការពាររុក្ខជាតិ (ហៅថាថ្នាំកម្ចាត់សត្វល្អិត) និងចំណីសត្វពាហនៈនៅប្រទេសវៀតណាមៈ

កសិករខ្មែរដែលរស់នៅជិតព្រំដែនចម្ងាយពី ១០ ទៅ ២០ គីឡូម៉ែត្រ មានកសិដ្ឋានធំៗនិងមានលុយគ្រប់គ្រាន់ គាត់ទិញជី និងថ្នាំកម្ចាត់សត្វល្អិតដោយផ្ទាល់ពីទីផ្សារវៀតណាម ដោយសារគាត់អាចរកបាននូវផលិតផលដែលមានគុណភាពខ្ពស់និងមានការណែនាំពីរបៀបប្រើប្រាស់ផលិតផល។

កសិករខ្មែរផ្សេងទៀត ជាធម្មតា គាត់ទិញជីនិងថ្នាំកម្ចាត់សត្វល្អិតពីហាងលក់ទំនិញនៅកម្ពុជា។

ការស្រាវជ្រាវនេះជួបប្រទះនូវបញ្ហាប្រឈមជាច្រើនក្នុងការអង្កេតអំពីតម្លៃជី និងថ្នាំកម្ចាត់សត្វល្អិត។ ម្ចាស់ហាងភាគច្រើនមិនចង់ផ្តល់ព័ត៌មានឬផ្តល់ព័ត៌មានមិនត្រឹមត្រូវដល់ក្រុមសិក្សា ពីព្រោះការប្រកបអាជីវកម្មនេះនៅតាមតំបន់ព្រំដែនគឺជាបញ្ហារសើប ថែមទាំងមានការប្រកួតប្រជែងខ្លាំងក្នុងចំណោមហាងនិងតូបលក់ទំនិញនៅតាមព្រំដែន។

[2] ប្រេងម៉ាសូត និងប្រេងសាំង ត្រូវបានហាមឃាត់មិនឱ្យធ្វើការនាំចេញ ប៉ុន្តែជារឿយៗ ប្រេងម៉ាសូត និងប្រេងសាំងត្រូវបានជួញដូរនៅតាមច្រកព្រំដែនបន្ទាប់បន្សំ ។

## ២.៣ ការរៀបចំ រចនាសម្ព័ន្ធ និងបណ្ដាញចែកចាយនៅលើទីផ្សារ

### ២.៣.១ ស្រូវ

#### ក. ពេលវេលានៃការធ្វើអាជីវកម្មស្រូវ

- ខេត្តតាកែវគឺជាទីកន្លែងដ៏សំខាន់សម្រាប់ការជួញដូរស្រូវស្រាល IR504[3] ដែលបានដាំដុះនៅក្នុងខេត្តតាកែវ កំពត កំពង់ស្ពឺ និងកំពង់ឆ្នាំង ដើម្បីនាំចេញទៅប្រទេសវៀតណាម។ ស្រូវធ្ងន់ប្រភេទម្លិះ[4] ត្រូវបានដឹកជញ្ជូនពីខេត្តកំពង់ធំ បាត់ដំបង សៀមរាប ពោធិ៍សាត់... និងឆ្លងកាត់ខេត្តតាកែវ។

ស្រូវ IR 504 ជាធម្មតា ត្រូវបានដាំដុះចំនួនពីរដង[5] ក្នុងមួយឆ្នាំនៅខេត្តតាកែវ រីឯតំបន់មួយចំនួនទៀតនៅក្បែរប្រទេសវៀតណាមធ្វើការដាំដុះចំនួនបីដង ក្នុងមួយឆ្នាំ។

- ខេត្តស្វាយរៀងជាកន្លែងជួញដូរស្រូវ IR504 សម្រាប់រយៈពេលកន្លះឆ្នាំ និងកន្លះឆ្នាំទៀតជួញដូរស្រូវម្លិះ[6]។

**តារាង១៖ ពេលវេលានៃការធ្វើអាជីវកម្មនៅខេត្តតាកែវ និងស្វាយរៀង**

| ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| តាកែវ | | | | | | | | | | | | |
| ស្វាយរៀង | | | | | | | | | | | | |

Lúa ngắn ngày IR 504

Lúa dài ngày Malis

Thời điểm mua bán sản lượng lớn:

[3] ស្រូវស្រាល ត្រូវចំណាយពេល ៩០ថ្ងៃ ដើម្បីប្រមូលផលក្នុងមួយរដូវ។ ស្រូវប្រភេទនេះ មានគ្រាប់ខ្លីៗ និងពណ៌ស្រអាប់។

[4] ស្រូវធ្ងន់ ត្រូវចំណាយពេល ១២០-១៥០ថ្ងៃ ដើម្បីប្រមូលផលក្នុងមួយរដូវ។ ស្រូវប្រភេទនេះ មានគ្រាប់វែងៗ និងពណ៌ស។

[5] ហាងលក់ដុំជាច្រើននៅក្នុងរបាយការណ៍ទីញបៀនបង្ហាញថាកសិករកម្ពុជាដាំដុះស្រូវ IR504 នៅតាមតំបន់ទាំងឡាយដែលមានទឹក ហើយកសិករកម្ពុជាស្វែងរកវិធីសាស្ត្រផ្សេងៗដើម្បីបានទឹកសម្រាប់ផ្គត់ផ្គង់ដល់ការធ្វើស្រែទាំងទឹកលើដី និងទឹកក្រោមដី។

[6] ស្រូវធ្ងន់ ប្រភេទម្លិះ ជាធម្មតា ត្រូវបានសាបព្រោះនៅខែឧសភា ឬ ខែមិថុនា និងត្រូវបានប្រមូលផលចាប់ពីខែតុលា ដល់ខែធ្នូ។ កសិករខ្មែរមិនលក់ស្រូវម្លិះភ្លាមៗនោះទេ ពីព្រោះពួកគេធ្វើការស្តុកទុកស្រូវម្លិះសិនបន្ទាប់ពីធ្វើការច្រូតកាត់ហើយ។

## ខ. តម្លៃផលិតផលនៅលើទីផ្សារ

### តារាង២៖ តម្លៃស្រូវ IR504 ជាមធ្យមនៅក្នុងខេត្តតាកែវ និងស្វាយរៀង

| | ដុង | (១) | (២) | (៣) | (៤) | (៥) | (៦) | (៧) |
|---|---|---|---|---|---|---|---|---|
| ស្រូវ IR504 | ដុង/គ.ក | ៣.២០០ | ៣.៤០០ | ៤.១០០ | ៤.២០០ | ៤.៦០០ | ៦.៣៥០ | ៧.៩៩០ |
| | រៀល/គ.ក | ៦៤០ | ៦៨០ | ៨២០ | ៨៦០ | ៩២០ | ១.២៧០ | ១.៥៩៨ |
| ថ្លៃដឹកជញ្ជូន និងកម្មករ | ដុង/គ.ក | | ៨០ | ៣៥០ | ៥០ | ២០០ | ១.៤០០ | ៦៥០ |
| ថ្លៃឈ្នួលផ្សេងៗ | ដុង/គ.ក | | | ២០០ | ២០ | ០ | ០ | ២០០ |
| ចំណេញសុទ្ធ | ដុង/គ.ក | | ១២០ | ១៥០ | ៣០ | ២០០ | ៣៥០ | ៧៩០ |
| | រៀល/គ.ក | | ២៤ | ៣០ | ៦ | ៤០ | ៧០ | ១៥៨ |

ប្រភព៖ ការអង្កេតដែលបានធ្វើឡើងចាប់ពីថ្ងៃទី៦ ខែមករា ដល់ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ នៅខេត្តតាកែវ និងស្វាយរៀង

សម្គាល់៖

(១) កសិករខ្មែរ

(២) អ្នកប្រមូលទិញក្នុងស្រុក

(៣) អ្នកប្រមូលទិញ/អ្នកដឹកជញ្ជូនជនជាតិខ្មែរ

(៤) អ្នកលក់ដុំជនជាតិវៀតណាម

(៥) ឈ្មួញវៀតណាម

(៦) តំបន់កែច្នៃស្រូវ

(៧) ក្រុមហ៊ុននាំចេញ (HCM)

ស្រូវធ្ងន់ប្រភេទម្លិះ និង Soc ជាមធ្យមមានតម្លៃ ២.៥០០ដុង (~៥០០រៀល) ថ្លៃជាងស្រូវ IR 504 ដែលផលិតនៅប្រទេសកម្ពុជា។ ឧទាហរណ៍ ស្រូវ IR 504 នៅខេត្តស្វាយរៀង នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ មានតម្លៃ ៣.៥០០ដុង/គីឡូក្រាម(~៧០០រៀល/គីឡូក្រាម) បើប្រៀបធៀបនឹងស្រូវម្លិះពីខេត្តស្ទឹងត្រែងមានតម្លៃ៦.៣០០ដុង/គីឡូក្រាម (~១.២៦០រៀល/គីឡូក្រាម)។

- តម្លៃស្រូវ IR 504 នៅខេត្តស្វាយរៀង ជាធម្មតាមានតម្លៃ ១០០-២០០ដុង/គីឡូក្រាម (~២០-៤០រៀល/គីឡូក្រាម) ថ្លៃជាងស្រូវ IR 504 នៅប្រទេសវៀតណាម។ រីឯតម្លៃស្រូវ IR 504 នៅខេត្តតាកែវ ជាធម្មតាមានតម្លៃចាប់ពី៥០-១០០ដុង/គីឡូក្រាម (~១០-២០រៀល/គីឡូក្រាម) ថោកជាងស្រូវ IR 504 របស់

ប្រទេសវៀតណាម។ យោងតាមអាជីវករបានឲ្យដឹងថា កសិករនៅខេត្តស្វាយរៀងប្រើប្រាស់ថ្នាំគីមីនិងជីតិចជាងកសិករនៅខេត្តតាកែវ។ កសិករនៅខេត្តស្វាយរៀងប្រើប្រាស់ជីតិច ដូច្នេះស្រូវទទួលបានទិន្នផលតិច ប៉ុន្តែវាមានគុណភាពល្អជាងស្រូវនៅខេត្តតាកែវ (ប្រើប្រាស់ជីគីមីតិច ធ្វើឱ្យស្រូវខូចមានកម្រិតទាប)។ លើសពីនេះ បច្ចេកទេសនៃការរក្សាទុកស្រូវបន្ទាប់ពីការច្រូតកាត់ក៏ល្អជាងដែរ (គ្រាប់អង្ករស្អាត) ។ ម្យ៉ាងវិញទៀត ស្រូវ IR 504 នៅខេត្តតាកែវមានតម្លៃថោកជាងស្រូវ IR 504 នៅប្រទេសវៀតណាមពីព្រោះវាមិនសុទ្ធល្អពណ៌អង្ករស្រអាប់ ហើយបច្ចេកទេសទុកដាក់ស្រូវបន្ទាប់ពីការច្រូតកាត់មិនសូវល្អ (អង្ករមិនសុទ្ធល្អ) និងត្រូវបានបំផ្លាញដោយសារសត្វល្អិត។

## គ. សង្វាក់នៃការចែកចាយស្រូវ

ដ្យាក្រាម១៖ បណ្តាញចែកចាយស្រូវពីប្រទេសកម្ពុជាទៅប្រទេសវៀតណាម




*សម្គាល់៖

- នៅតំបន់មួយចំនួនដែលស្ថិតនៅឆ្ងាយពីព្រំដែនវៀតណាមចំងាយ១-១០ គីឡូម៉ែត្រ អ្នកប្រមូល ក្នុងស្រុក (២) ជាធម្មតា លក់ដោយផ្ទាល់ទៅអ្នកលក់ដុំ/ឈ្មួលកណ្តាល (៤)។
- ឈ្មួញវៀតណាម (៥) ទិញស្រូវធ្ងន់ (ម្លិះ) សម្រាប់លក់ទៅទីផ្សារក្នុងស្រុក។ ឈ្មួញទាំងនេះ ជាធម្មតា កិនស្រូវនៅរោងម៉ាស៊ីនកិនស្រូវក្នុងស្រុកដែលមានចំងាយប្រហែល ៥០ គីឡូម៉ែត្រ ពីព្រំដែន ជំនួសឲ្យការ

កិនស្រូវនៅតំបន់កែច្នៃស្រូវ។ ដូច្នេះ ពួកគេមិនចាំបាច់ដឹកជញ្ជូនស្រូវទៅតំបន់កែច្នៃស្រូវដែលស្ថិតនៅឆ្ងាយពីព្រំដែននោះទេ។

## ឃ. ការរៀបចំ និងលក្ខណៈនៃបណ្ដាញទីផ្សារស្រូវ

### (១) កសិករកម្ពុជាលក់ស្រូវសើម

កសិករកម្ពុជាលក់ស្រូវសើម (លក់ភ្លាមៗបន្ទាប់ពីច្រូតរួច) និងលក់ស្រូវស្ងួត (លក់បន្ទាប់ពីសំងួតរួច)។ ទោះជាយ៉ាងណាក៏ដោយ សព្វថ្ងៃនេះ កសិករកម្ពុជា និងអ្នកប្រមូលទិញ ចូលចិត្តទិញលក់ស្រូវសើម។

- កសិករដែលមានផ្ទៃដីតិចជាង ១ហិកតា ឬមានដីនៅជិតព្រំដែនវៀតណាម (ប្រហែល១-១០គីឡូម៉ែត្រ) តែងតែលក់ស្រូវទៅឱ្យអ្នកប្រមូលក្នុងស្រុក (២)។

### (២) អ្នកប្រមូលក្នុងស្រុក

អ្នកប្រមូលក្នុងស្រុក គឺជាប្រជាជនដែលរស់នៅក្នុងឃុំជាមួយនឹងកសិករ ហើយពួកគេមានរថយន្តដឹកទំនិញធម្មតា (ចំណុះចាប់ពី ១-៥តោន) និងមានទំនាក់ទំនងជិតស្និទ្ធជាមួយកសិករព្រមទាំងធ្លាប់ឱ្យកសិករខ្ចីលុយដើម្បីធ្វើស្រែទៀតផង។

- អ្នកប្រមូលទិញក្នុងស្រុកបានរក្សាទុកស្រូវ ៨០% នៅផ្ទះ ឬនៅក្នុងឃ្លាំងរបស់ពួកគេរយៈពេលពី ២-៥ថ្ងៃ បន្ទាប់មក ទើបពួកគេលក់ស្រូវទៅឱ្យអ្នកប្រមូល/អ្នកដឹកជញ្ជូន (៣) ប្រហែល២០% នៃស្រូវរបស់អ្នកប្រមូលក្នុងស្រុក (២) ដែលរស់នៅជិតព្រំដែនវៀតណាមបានលក់បន្តទៅឱ្យអ្នកបោះដុំ (៤)។

### (៣) អ្នកប្រមូលទិញ/អ្នកដឹកជញ្ជូន

អ្នកប្រមូលទិញ/អ្នកដឹកជញ្ជូនជាអ្នកប្រមូលនិងដឹកជញ្ជូនស្រូវស្រាល និងស្រូវធ្ងន់ តែងតែមានរថយន្តដឹកទំនិញចំណុះចាប់ពី ២០-៤០ តោនសម្រាប់ដឹកស្រូវចម្ងាយពី ១០០-៤០០គីឡូម៉ែត្រ ហើយពួកគេមានទំនាក់ទំនងជាមួយអ្នកលក់ដុំជាច្រើនកន្លែងនៅតាមព្រំដែន។

ថៅកែរបស់អ្នកប្រមូល/អ្នកដឹកជញ្ជូន ជាធម្មតា មិនធ្វើការដឹកជញ្ជូនផលិតផលដោយផ្ទាល់ទេ ពួកគេនៅផ្ទះ និយាយទូរស័ព្ទចាត់ចែងការងារប្រមូលទិញ ស្ទាបស្ទង់តម្លៃនៅវៀតណាម និងជ្រើសរើសទីតាំងសម្រាប់លក់។ លើសពីនេះ ដើម្បីបំពេញតួនាទីជាអ្នកលក់ដុំ តម្រូវឱ្យថៅកែផ្ទាល់ មាន "ទំនាក់ទំនងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងយល់ច្បាស់អំពីច្បាប់ពាណិជ្ជកម្ម"។ ដោយសារតែរថយន្តដឹកទំនិញភាគច្រើនផ្ទុកលើសចំណុះ (ចំណុះជាមធ្យមស្មើនឹង ៣០ តោន នៅខេត្តតាកែវការដឹកជញ្ជូនមានចំណុះស្មើនឹង ៤០ តោន) ក្នុងការឆ្លងកាត់ផ្លូវ និងស្ពាន ដូច្នេះ បើទោះជាសហគមន៍កសិកម្មមានដើមទុន រថយន្តដឹកទំនិញ ផែនការអាជីវកម្មក៏ដោយក៏សហគមន៍កសិកម្មមិនប្រាកដថាខ្លួនអាចធ្វើអាជីវកម្មបានដោយជោគជ័យជាមួយវៀតណាមនៅតាមព្រំដែនដែរ។

ជាធម្មតា ប្រជាជននៅតាមតំបន់ព្រំដែនមិនប្រើលុយដើម្បីទូទាត់ថ្លៃទំនិញទេ (ប្រើលុយក្នុងករណីលក់ដូរតិចតួច ឬលក់ទៅឱ្យអតិថិជនចម្លែកប៉ុណ្ណោះ)។ បន្ទាប់ពីធ្វើការលក់ដូរ (៣) និងបូកសរុបតម្លៃរួច ពួកគេធ្វើការទូទាត់លុយដោយផ្ទេរប្រាក់តាមធនាគារ ឬតាមអ្នកតំណាង។

ក្នុងចំណោមអាជីវករជួញដូរអង្ករនៅលើទីផ្សារ ភ្នាក់ងារទិញលក់អង្ករកប្រាក់ចំណេញបានច្រើនជាងគេ (ជាមធ្យមប្រហែល ៣០០ ដុង/គីឡូក្រាម ~ ៦ រៀល/គីឡូក្រាម) ប៉ុន្តែភ្នាក់ងារនេះក៏ប្រឈមនឹងហានិភ័យខ្ពស់ដែរ ពីព្រោះពួកគេ "ទិញទាំងអស់ និងលក់វិញទាំងអស់" ជាមួយកសិករ និងអ្នកប្រមូលក្នុងស្រុក។ ប្រសិនបើតម្លៃស្រូវនៅវៀតណាមឡើងថ្លៃខ្ពស់ ពួកគេនឹងរកប្រាក់ចំណេញបានច្រើន ប៉ុន្តែប្រសិនបើតម្លៃស្រូវចុះថោកវិញ ពួកគេខាត។ លើសពីនេះ ពួកគេត្រូវបង់ថ្លៃសេវាកម្មជាច្រើនទៀតនៅតាមផ្លូវនៅក្នុងប្រទេសកម្ពុជា (ប៉ុស្តិ៍ត្រួតពិនិត្យនីមួយៗ មានថ្លៃសេវាកម្មខុសៗគ្នាអាស្រ័យលើការទំនាក់ទំនង) រីឯថ្លៃចំណាតរថយន្តនៅប្រទេសវៀតណាមវិញគឺស្មើនឹង ២០០ ដុង/គីឡូក្រាម ~ ៤០រៀល/គីឡូក្រាម)។

### (៤) អ្នកលក់ដុំ

អ្នកលក់ដុំ គឺជាបុគ្គលដែលមានទីតាំងអាជីវកម្មនៅតាមព្រំដែន មានឃ្លាំងស្រូវជាច្រើនកន្លែង មានចំណតរថយន្ត ឬចំណតនាវាច្រើន មានដើមទុនច្រើន មានទំនាក់ទំនងជាមួយអតិថិជនជាច្រើន នៅក្នុងតំបន់កៃច្នៃស្រូវធំៗនៃប្រទេសវៀតណាម (ចូថាញ់-អានយ៉ាង ថុត ណុត-កាន់ថូ សាដិក ឡាប់វ៉ូ-ដុងថាប់ វិញឡុង កៃឡាយ-ទៀនយ៉ាង) មានទំនាក់ទំនងល្អជាមួយភ្នាក់ងាររដ្ឋាភិបាលនៅតាមព្រំដែននៃប្រទេសទាំងពីរ។

លទ្ធផលនៃការអង្កេតនេះបង្ហាញថា ៥០% នៃអ្នកលក់ដុំជាជនជាតិវៀតណាម ២០% ជាជនជាតិវៀតណាមប៉ុន្តែបានរៀបការជាមួយជនជាតិកម្ពុជាដែលធ្វើការនៅក្នុងជួររដ្ឋាភិបាល ហើយ ៣០% ទៀតគឺជាមន្ត្រីរាជការកម្ពុជាដែលប្រកបអាជីវកម្មខ្លួនឯងដោយផ្ទាល់។

អ្នកលក់ដុំដឹងអំពីព័ត៌មាន និងបទប្បញ្ញត្តិទាំងអស់នៅក្នុងតំបន់អាជីវកម្ម ព័ត៌មានអំពីថៅកែពិតប្រាកដរបស់អតិថិជន និងអ្នកលក់នៅកម្ពុជានិងនៅវៀតណាម។ ដូច្នេះហើយទើបអ្នកដឹកជញ្ជូនកម្ពុជា (៣) ឬឈ្មួញវៀតណាម (៥) ជឿជាក់លើការធ្វើអាជីវកម្ម (ទោះបីជាមិនទាន់ទូទាត់លុយក៏ដោយ)។

ខេត្តនីមួយៗនៅតាមតំបន់ព្រំដែនមានទីតាំងទិញស្រូវចាប់ពី ៣-៥ កន្លែង ដែលមានអ្នកលក់ដុំជាច្រើន ហើយមានកន្លែងទិញស្រូវធំជាងគេបង្អស់មួយ ដែលជារៀយៗទិញស្រូវប្រហែលពី ៦០% - ៧០% នៃទិន្នផលស្រូវទាំងអស់របស់ខេត្ត។

+ ខេត្តតាកែវ ស្រុកគិរីវង់ ឃុំថាំដូង ភូមិតារុំហាមលិត (ជាប់ព្រំប្រទល់ស្រុកតាន់បៀន ខេត្តអានយ៉ាង) គឺជាកន្លែងទិញស្រូវដ៏ធំបំផុត។ មានកន្លែងលក់ដុំធំៗចំនួនប្រាំពីរកន្លែងដែលធ្វើការជួញដូរស្រូវជារៀងរាល់ថ្ងៃចាប់ពី១.០០០-២.៥០០ តោន នៅ



រូបភាពទី៥៖ ផ្សារលក់ដុំស្រូវធំបំផុត
គិរីវង់-តាកែវ, អានយ៉ាង-ទីញបៀន

រដូវលក់ដាច់ និងចាប់ពី៣០០-៥០០តោន នៅរដូវមិនសូវលក់ដាច់ នៅក្នុងការជួញដូរនេះ ស្រូវប្រហែល៧0% គឺជាស្រូវ IR504។ នៅខែប្រាំង (ខែធ្នូ- ខែកក្កដា) កន្លែងទិញស្រូវមានទីតាំងនៅវៀតណាម និងនៅរដូវទឹកជំនន់ (ខែសីហា- ខែវិច្ឆិកា) កន្លែងទិញស្រូវបានផ្លាស់ទីតាំងទៅទឹកដីប្រទេសកម្ពុជាចម្ងាយប្រហែល១គីឡូម៉ែត្រ ពីព្រំដែនប្រទេសវៀតណាម។

+ ខេត្តស្វាយរៀង ស្រុកកំពង់រោទិ៍ ភូមិព្រៃរល្លិ (ជាប់ព្រំដែន ភូមិប៊ីញហៀប ស្រុកម៉ុកហោ ខេត្តឡុងអាន) គឺជាកន្លែងជួញដូរស្រូវធំជាងគេបង្អស់ក្នុងខេត្តស្វាយរៀងដែលធ្វើការជួញដូរស្រូវរហូតដល់៦០%នៃទិន្នផលស្រូវសរុបនៅក្នុងខេត្តនេះ (កន្លែងជួញដូរស្រូវធំទី២ គឺនៅភូមិក្រូ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀងជាប់ព្រំប្រទល់ភូមិទី១ ឃុំហ៊ុងដៀន ស្រុកវិញហ៊ុង ខេត្តឡុងអាន)។ កន្លែងលក់បោះដុំស្រូវធំៗចំនួនបួនកន្លែង នៅភូមិព្រៃរល្លិ ខេត្តស្វាយរៀងដែលធ្វើការជួញដូរស្រូវជារៀងរាល់ថ្ងៃ ចាប់ពី ១.០០០ តោន - ២.០០០ តោន នៅរដូវមមាញឹក និង ១០០- ៦០០ តោន នៅរដូវមិនសូវមមាញឹក។ ស្រូវប្រហែល៥0% ដែលជួញដូរគឺជាប្រភេទស្រូវ IR504 ហើយ៥0% ទៀតគឺជាប្រភេទស្រូវធ្ងន់ ដូចជា ម្លិះ និង Soc។

ខុសពីខេត្តតាកែវ ទីតាំងជួញដូរស្រូវនៅខេត្តស្វាយរៀងមិនសូវមានភាពមមាញឹកទេនៅរដូវប្រមូលផលស្រូវ IR504 ប៉ុន្តែមានការជួញដូរជាប្រចាំ និងបន្តបន្ទាប់ព្រោះទិន្នផលស្រូវ ៥0% ដែលទិញដូរគឺជាប្រភេទស្រូវធ្ងន់ដូចជាស្រូវម្លិះ។ អតិថិជនជនជាតិវៀតណាមនិយមទិញស្រូវម្លិះដែលជាធម្មតាវាមានតម្លៃខ្ពស់ដើម្បីបរិភោគជាលក្ខណៈគ្រួសារក្នុងប្រទេសវៀតណាម។

អ្នកលក់ដុំមិនទទួលបានប្រាក់ចំណេញច្រើនទេនិងមានការប្រែប្រួលបន្តិចបន្តួច ប៉ុន្តែការប្រែប្រួលនេះមិនអាស្រ័យលើតម្លៃទីផ្សារឡើយ ។ ប្រាក់ចំណេញសុទ្ធដែលទទួលបានមានប្រហែល ២0-៥0 ដុង/គីឡូក្រាម ឬ ៥-១0 រៀល/គីឡូក្រាម។ ទោះជាយ៉ាងណាក៏ដោយ អ្នកលក់ដុំទទួលបានប្រាក់ចំណូលច្រើនពីមុខរបររកស៊ីរបស់គាត់ដោយសារគាត់ជួញដូរស្រូវក្នុងបរិមាណច្រើន។

លទ្ធផលនៃការអង្កេតក៏បានទទួលព័ត៌មានពីអ្នកលក់ដុំផងដែរថាស្រូវម្លិះខ្មែរត្រូវបានប្រើប្រាស់មិនត្រឹមតែក្នុងស្រុកទេ ថែមទាំងសម្រាប់នាំចេញផងដែរ ។ ប៉ុន្តែ យើងមិនអាចស្វែងរកព័ត៌មានណាដែលដែលបង្ហាញពីការនាំចេញស្រូវម្លិះ

ខ្មែរទេ។ យើងបានរកឃើញព័ត៌មានជាច្រើនដែលទាក់ទងនឹងស្រូវម្លិះរបស់កម្ពុជាបានលក់ឱ្យអតិថិជននៅតំបន់ដីសណ្តទន្លេមេគង្គគឺទីក្រុងហូជីមិញ និងទីក្រុងហាណូយ (ភាគខាងជើងប្រទេសវៀតណាម)។

**(៥) ឈ្មួញជួញដូរស្រូវ (ជនជាតិវៀតណាម)**

- ពួកគេមានមធ្យោបាយដឹកជញ្ជូនស្រូវតាមនាវា (២០-១០០ តោន ក្នុងមួយកប៉ាល់ និង ២០០-៥០០ តោន ក្នុងមួយនាវាដឹកទំនិញធំៗ) ពួកគេ ១០០% ជាជនជាតិវៀតណាម។ ការរកស៊ីចម្បងរបស់ពួកគេគឺទិញស្រូវពីកន្លែងផ្សេងៗ ហើយដឹកជញ្ជូនទៅតំបន់កែច្នៃនៅតំបន់ដីសណ្តទន្លេមេគង្គដើម្បីលក់ស្រូវនោះ ឬកិន និងលក់អង្ករសម្រូបទៅឱ្យក្រុមហ៊ុនកែច្នៃនិងក្រុមហ៊ុននាំចេញ។ ចាប់ពីឆ្នាំ ២០១៣ មក ពួកគេនិយមទិញស្រូវរួចដឹកជញ្ជូនទៅតំបន់កែច្នៃ ហើយកិនជាអង្ករសម្រូបលក់ឱ្យក្រុមហ៊ុនកែច្នៃនិងក្រុមហ៊ុននាំចេញដោយសារពួកគេអាចលក់អនុផលិតផលស្រូវដូចជាអង្កាម កន្ទក់ដែលមានតម្លៃខ្ពស់ជាងឆ្នាំមុនៗ ឬពួកគេអាចទទួលបានប្រាក់ ២០-៣០ដុង/គីឡូក្រាម ពីរោងម៉ាស៊ីនកិនស្រូវ (ដោយទុកអង្កាមនិងកន្ទក់ឱ្យរោងម៉ាស៊ីន)។

តារាងទី៣៖ រោងម៉ាស៊ីនកិនស្រូវសម្រាប់នាំចេញ តំបន់កៃច្នៃនៅតំបន់ដីសណ្តទន្លេមេគង្គ និងចម្ងាយផ្លូវពីព្រំប្រទល់ខេត្តតាកែវ និងខេត្តស្វាយរៀង

| ឈ្មោះតំបន់កៃច្នៃស្រូវ | ចម្ងាយផ្លូវពីព្រំប្រទល់ខេត្តតាកែវ (គីឡូម៉ែត្រ) | ចម្ងាយផ្លូវពីព្រំប្រទល់ខេត្តស្វាយរៀង (គីឡូម៉ែត្រ) |
|---|---|---|
| ខេត្តចូថាញ់-ទីញអានយ៉ាង | ៧០ | |
| ខេត្តតាន់ចូ-អានយ៉ាង | ៦០ | |
| ខេត្តចុតណុត- TP កាន់ថូ | ៩០ | |
| ខេត្តឡាប់វ៉ូ-ដុងថាប់ | ៩០ | |
| ខេត្តសាដិក-ដុងថាប់ | (*)១១០ | ១៥០ |
| ខេត្តកៃបេ-ទៀនយ៉ាង | (**)១៧០ | (*)១០០ |
| ខេត្តកៃឡាយ-ទៀនយ៉ាង | ១៩០ | ១១០ |
| ខេត្តម៉ុកហូ-ឡុងអាន | | ៦០ |
| ខេត្តតាន់អាន-ឡុងអាន | | (**)១៣០ |

(ប្រភព៖ លទ្ធផលនៃការអង្កេតនៅខែមករា ឆ្នាំ២០១៥ នៅខេត្តតាកែវនិងស្វាយរៀង)

(*) (**)៖ ទីតាំងដែលមនុស្សជាច្រើនយកស្រូវទៅកិន ឬលក់

យោងតាមលទ្ធផលនៃការអង្កេតបានបង្ហាញថា គម្លាតតម្លៃរវាងការទិញនិងការលក់របស់អ្នកជំនួញជនជាតិវៀតណាមពីព្រំប្រទល់ទៅតំបន់កៃច្នៃស្រូវមានគម្លាតធំធេង។ ទោះជាយ៉ាងណាក៏ដោយ ហេតុផលចម្បងគឺដោយសារការបូកបញ្ចូលនូវតម្លៃនៃការដឹកជញ្ជូននិងប្រាក់ឈ្នួលកម្មករ។ ប្រាក់ចំណេញសុទ្ធជាមធ្យមគឺប្រហែល ២០០ដុង/គក (ប្រហែល៤០រៀល/គក) រីឯហានិភ័យក៏ខ្ពស់ដែរ ព្រោះតម្លៃទីផ្សារមានការប្រែប្រួល។

ការស្រាវជ្រាវបានបង្ហាញថា ៩០% នៃអ្នកជំនួញជនជាតិវៀតណាម ដែលបានស្ទង់មតិនិយមទិញស្រូវម្លិះពីប្រទេសកម្ពុជាដោយសារវាមានគុណភាព ល្អ រសជាតិឆ្ងាញ់ អត្រាខូតខាតស្រូវមានកម្រិតទាប និងមានតម្លៃថេរ។ លើសពីនេះ ៨០% នៃអ្នកជំនួញជនជាតិវៀតណាមដែលបានស្ទង់មតិបញ្ជាក់ថាពួកគេចូលចិត្តទិញស្រូវ IR504 ពីប្រទេសកម្ពុជាព្រោះអត្រាកន្ទកតិចជាងស្រូវ IR504 របស់ប្រទេសវៀតណាម។ ម្យ៉ាងទៀតសំណើមនៃស្រូវទាបហើយស្រូវខូចក៏មានកម្រិតទាបជាងដែរ។

### (៦) អ្នកនាំចេញ

- អ្នកនាំចេញអង្ករដ៏ធំនៅប្រទេសវៀតណាមទិញស្រូវ IR504 ពីប្រទេសកម្ពុជាហើយកិនជាអង្ករសម្រាប់នាំចេញជាចម្បងទៅកាន់ទីផ្សារដែលខ្វះខាតអង្ករដូចជាទីផ្សារប្រទេសចិន និងអាហ្វ្រិកមានតែបរិមាណអង្ករតិចតួចប៉ុណ្ណោះដែលដាក់លក់នៅលើទីផ្សារក្នុងស្រុក។
- ក្រុមហ៊ុនតូចៗមួយចំនួន ឬរោងម៉ាស៊ីនកិនស្រូវនៅក្នុងប្រទេសវៀតណាមជារឿយៗទិញស្រូវពីប្រទេសកម្ពុជាយកទៅកិនហើយលក់នៅទីផ្សារក្នុងប្រទេសវៀតណាម (ជាពិសេសនៅតំបន់ដីសណ្តទន្លេមេគង្គ និងទីក្រុងហូជីមិញ) និងមួយផ្នែកតូចត្រូវបានវេចខ្ចប់ក្នុងកញ្ចប់ត្រឹមត្រូវដើម្បីនាំចេញទៅកាន់ទីផ្សារចង្អៀត ដូចជាអេមីរ៉ាតអារ៉ាប់រួម និងអឺរ៉ុប។

### សម្គាល់៖

ការសិក្សាស្រាវជ្រាវរកឃើញថាអង្ករសម្រិតប្រភេទ ST5 OM1490 ជួនកាលត្រូវនាំចេញត្រឡប់មកប្រទេសកម្ពុជាតាមខេត្តតាកែវ កណ្តាល ព្រៃវែង និងស្វាយរៀង។ យើងបានរកឃើញមូលហេតុនៃការនាំចេញអង្ករសម្រិតរបស់ប្រទេសវៀតណាមមកប្រទេសកម្ពុជាគឺមិនមែនសម្រាប់ប្រើប្រាស់នៅក្នុងទេសកម្ពុជាទេ តែវាសម្រាប់នាំចេញបន្តទៅលក់នៅប្រទេសថៃ។

### ២.៣.២ ផ្លែស្វាយ

#### ក. តម្លៃផ្លែស្វាយ

**តារាងទី៣៖ តម្លៃផ្លែស្វាយរបស់ប្រទេសកម្ពុជាជាមធ្យម**

| | ឯកតា | (១) | (២) | (៣) | (៤) | (៥) |
|---|---|---|---|---|---|---|
| Xoai keo/ស្វាយរបស់កម្ពុជា | ដុង/គក | ៤.៥០០ | ៦.៥០០ | ១៥.០០០ | ១៧.៥០០ | ១៩.០០០ |
| | រៀល/គក | ៩០០ | ១.៣០០ | ៣.០០០ | ៣.៥០០ | ៣.៨០០ |
| ថ្លៃដឹកជញ្ជូន | ដុង/គក | | ១០០ | ២០០ | ១០០ | |
| ថ្លៃពលកម្ម | ដុង/គក | | ៣០ | ៤០០ | ០ | |
| ថ្លៃផ្សេងៗ | ដុង/គក | | ៣០ | ១០០ | | ០ |
| ប្រាក់ចំណេញសុទ្ធ | ដុង/គក | | ២៤០ | ១.០០០ | ៤០០ | |
| | រៀល/គក | | ៤៨ | ២០០ | ៨០ | |

សម្គាល់៖ ប្រភព៖ ការស្ទង់មតិនៅខែមករា ឆ្នាំ២០១៥ ក្នុងខេត្តតាកែវ និងស្វាយរៀង

(១) កសិករខ្មែរ

(២) អ្នកដឹកជញ្ជូន/អ្នកប្រមូលជនជាតិខ្មែរ

(៣) អ្នកលក់ដុំជនជាតិវៀតណាម

(៤) អ្នកជំនួញជនជាតិវៀតណាម

(៥) អតិថិជនជនជាតិវៀតណាម

**សម្គាល់**

- អ្នកលក់រាយជនជាតិវៀតណាមជាច្រើនបាននិយាយថាតម្លៃស្វាយរបស់កម្ពុជាពីខែកញ្ញា ដល់ខែធ្នូ មានតម្លៃខ្ពស់ណាស់ព្រោះឆ្នាំសិក្សាថ្មីក្នុងប្រទេសវៀតណាមគឺចាប់ផ្ដើមពីខែកញ្ញា ហើយស្វាយវៀតណាមនៅរដូវកាលនេះគឺប្រមូលផលបានតិច។ លើសពីនេះទៅទៀត ពួកគេបានដឹកជញ្ជូនស្វាយកម្ពុជាទៅភាគខាងជើងនៃប្រទេសវៀតណាម (ហាណូយ) ហើយពួកគេអាចលក់បានក្នុងតម្លៃខ្ពស់ព្រោះសម្បកស្វាយកម្ពុជារឹង ហើយងាយស្រួលក្នុងការដឹកជញ្ជូនតាមផ្លូវឆ្ងាយ។

## ខ. បណ្ដាញចែកចាយផ្លែស្វាយពីកម្ពុជាទៅវៀតណាម

- យោងតាមតួលេខពីគយប្រចាំច្រកព្រំដែនអន្តរជាតិទីញបៀន[7] ជារៀងរាល់ថ្ងៃមានស្វាយប្រហែល ៣៥ តោន ដឹកចេញពីខេត្តតាកែវលក់ទៅឱ្យប្រទេសវៀតណាម។ តែតួលេខជាក់ស្ដែងគឺខ្ពស់ជាងនេះ (យ៉ាងហោចណាស់មានស្វាយ ៩០តោន ត្រូវបានលក់ក្នុងមួយថ្ងៃនៅខេត្តតាកែវ) ព្រោះគយកត់ត្រាតែរថយន្តដឹកស្វាយតាមច្រកព្រំដែនប៉ុណ្ណោះ ប៉ុន្តែចំនួនស្វាយដ៏ច្រើនត្រូវបានដឹកជញ្ជូនចេញតាមព្រំដែនដោយយានយន្តរបស់អ្នកជំនួញដោយមិនបានរាយការណ៍ឡើយ។
- ខេត្តតាកែវ (ច្រកព្រំដែនភ្នំដិន ស្រុកគិរីវង់) លក់ផ្លែស្វាយទៅឱ្យប្រទេសវៀតណាមច្រើនជាងគេបំផុតព្រោះអតិថិជនភាគច្រើនរស់នៅតំបន់ដីសណ្ដទន្លេមេគង្គ និងទីក្រុងហូជីមិញ។ លើសពីនេះអ្នកជំនួញបន្លែ ផ្លែឈើជាច្រើនចូលចិត្តប្រើច្រកព្រំដែនភ្នំដិន-ទីញបៀន[8] សម្រាប់រកស៊ីព្រោះវាជាច្រកតែមួយគត់ដែលបើកធ្វើការយូរជាងច្រកព្រំដែនផ្សេងៗទៀត។ម្យ៉ាងទៀតអាជ្ញាធរខេត្តតាកែវអនុញ្ញាតឱ្យរថយន្តផ្ទុកទំនិញលើសចំណុះឆ្លងកាត់តាមខេត្តតាកែវទៅរាជធានីភ្នំពេញ។

[7] ច្រកព្រំដែននៅភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ

[8] ចាប់តាំងពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ គណៈកម្មាធិការពលរដ្ឋខេត្តអានយ៉ាង និងខេត្តតាកែវបានយល់ស្របបើកច្រកព្រំដែនចាប់ពីម៉ោង ៥ព្រឹក ដល់ម៉ោង ១០យប់ ជំនួសឱ្យការបើកពីម៉ោង៥ព្រឹកដល់ម៉ោង៦ល្ងាច។

- ខេត្តស្វាយរៀងក៏បានលក់ស្វាយជារៀងរាល់ថ្ងៃទៅឱ្យប្រទេសវៀតណាមនៅតាមទីតាំងជាច្រើនកន្លែងតាមព្រំដែនដែរ ដូចនេះ តួលេខពិតប្រាកដមិនអាចកត់ត្រាបានឡើយ។ ស្វាយនៅខេត្តស្វាយរៀងភាគច្រើនលក់ឱ្យវៀតណាមសម្រាប់ទីផ្សារខេត្តឡុងអាន និងទីក្រុងហូជីមិញ។

- ផ្លែស្វាយកម្ពុជាលក់ទៅឱ្យវៀតណាមគិតជាកន្ត្រក[9] ដូច្នេះ ជាធម្មតាវាមានតម្លៃថោក។

ដ្យាក្រាមទី២៖ បណ្តាញចែកចាយផ្លែស្វាយពីកម្ពុជាទៅវៀតណាម




## គ. ការរៀបចំ និងលក្ខណៈនៃបណ្តាញទីផ្សារផ្លែស្វាយ

### (១) ផលិតផលស្វាយខ្មែរ

ការសិក្សាបង្ហាញថាកសិករខ្មែរភាគច្រើនមានចម្ការស្វាយតូចៗ។ ចម្ការមួយមានទំហំពី ០,១ ទៅ ០,៥ ហិកតាក្នុងខេត្តតាកែវ និងពី ០,១ ទៅ ០,៥ ក្នុងខេត្តស្វាយរៀង។

ជាទូទៅកសិករខ្មែរប្រមូលផលផ្លែស្វាយហើយលក់ឱ្យអ្នកប្រមូល/អ្នកដឹកជញ្ជូនគិតជាកន្ត្រក។ តម្លៃផ្លែស្វាយគឺ ៨០០-១.៣០០ រៀល/គីឡូក្រាម អាស្រ័យលើតម្លៃទីផ្សារ។

[9] ផ្លែស្វាយធំឬតូច ល្អឬខូច ខ្ចីឬទុំ ដាក់ចូលគ្នាដើម្បីលក់

**(២) អ្នកប្រមូល/អ្នកដឹកជញ្ជូន**

ពួកគាត់ជាជនជាតិខ្មែរដែលដឹងពីតំបន់មានស្វាយ រដូវប្រមូលផល និងបរិមាណផ្លែស្វាយ។ ពួកគាត់ប្រើរថយន្តធុនតូចដែលអាចផ្ទុកបានពី ៣-៥ តោន ហើយបើកចុះឡើងក្នុងភូមិដើម្បីប្រមូលផ្លែស្វាយ។ បន្ទាប់មក ពួកគាត់ដឹកជញ្ជូនផ្លែស្វាយទៅទល់ដែនវៀតណាម ហើយលក់ទៅឱ្យអ្នកលក់ដុំជនជាតិវៀតណាមជាកន្ត្រកដូចដែលពួកគាត់ទិញពីកសិករខ្មែរដែរ។

ក្រោយពីលក់ផ្លែស្វាយហើយ តាមធម្មតា ពួកគាត់ដឹកជញ្ជូនបន្លែផ្លែឈើផ្សេងពេលត្រឡប់ពីវៀតណាមវិញ។

**(៣) អ្នកលក់ដុំ**

ពួកគាត់គឺជាជនជាតិវៀតណាមហើយមានកន្លែងរកស៊ីជិតច្រកព្រំដែន ឬតាមព្រំដែន។ ចាប់ពីឆ្នាំ២០១៣មក អ្នកលក់ដុំមិនត្រឹមតែទិញផ្លែស្វាយកម្ពុជាពីប្រទេសកម្ពុជាទេ ថែមទាំងទិញដើមស្វាយកម្ពុជាទៅដាំក្នុងស្រុកទីញបៀន[10] និង ទ្រីតុន នៃខេត្តអានយ៉ាងប្រទេសវៀតណាមទៀតផង។

ក្រោយពេលទិញស្វាយកម្ពុជាជាកន្ត្រកហើយ អ្នកលក់ដុំបែងចែកស្វាយជាក្រុម លាងសម្អាត រួចវេចខ្ចប់ដើម្បីលក់។ ផ្លែស្វាយមានបីប្រភេទ៖ i) ផ្លែស្វាយប្រភេទទី១៖ ស្វាយមួយផ្លែមានទម្ងន់ជាង៥០០ក្រាម សំបកវាពណ៌បៃតងហើយរឹង ក្បាលវាលឿងព្រឿងៗ គ្មានការបំផ្លិចបំផ្លាញដោយសារសត្វល្អិតទេ ii) ផ្លែស្វាយប្រភេទទី២៖ ស្វាយមួយផ្លែមានទម្ងន់ចាប់ពី ៣០០ក្រាមទៅ៥០០ក្រាម មានសម្បកពណ៌បៃតងហើយរឹង ក្បាលវាលឿងព្រឿងៗ មានអុជៗដោយសារសត្វល្អិតស៊ី iii) ផ្លែស្វាយប្រភេទទី៣៖ ស្វាយមួយផ្លែមានទម្ងន់ក្រោម៣០០ក្រាម មានសម្បកពណ៌លឿងហើយទន់ ហើយខូចដោយសារសត្វល្អិតស៊ី។ ផ្លែស្វាយប្រភេទទី១ ដឹកទៅទីក្រុងហូជីមិញ ផ្លែស្វាយប្រភេទទី២ ជាទូទៅលក់ទៅឱ្យទីផ្សារនៃ

[10] ស្រុកទីញបៀន និងទ្រីតុនមានព្រំប្រទល់ជាប់ខេត្តតាកែវដូចគ្នា វាជាដីភ្នំ ហើយវាស្រដៀងនឹងដីកម្ពុជាដែរ។ កសិករជនជាតិវៀតណាមជាច្រើនមកកាន់ប្រទេសកម្ពុជាដើម្បីទិញគ្រាប់/ដើមស្វាយខ្មែរ ហើយបានដាំតាំងពីឆ្នាំ២០០៩មកម្ល៉េះ។ ចម្ការជាច្រើនបានប្រមូលផលតាំងពីឆ្នាំ២០១៣។ ស្វាយខ្មែរដែលដាំនៅវៀតណាមមានគុណភាពដូចនៅកម្ពុជាដែរ។

ខេត្តនៅតាមតំបន់ដីសណ្តទន្លេមេគង្គ ហើយស្វាយប្រភេទទី៣ ជាទូទៅលក់នៅផ្សារតូចៗនៅតំបន់ដាច់ស្រយាល។

លទ្ធផលនៃការស្ទង់មតិបានរកឃើញថា ជួនកាលអ្នកលក់ដុំវេចខ្ចប់ហើយដឹកស្វាយខ្មែរទៅលក់នៅប្រទេសចិន។ ទោះយ៉ាងនេះក្តីទីផ្សារប្រទេសចិនតូចចង្អៀត ហើយអ្នកលក់ដុំមិនចាប់អារម្មណ៍ទេពីព្រោះទីផ្សារនៅវៀតណាមធំជាង។ ម្យ៉ាងវិញទៀត យើងមិនអាចរកឃើញអ្នកលក់ដុំផ្លែស្វាយនៅខេត្តស្វាយរៀងទេ ព្រោះផ្លែស្វាយមកពីខេត្តស្វាយរៀងភាគច្រើនលក់ទៅឱ្យវៀតណាមតាមរយៈអ្នកលក់ដូរតាមផ្លូវជនជាតិវៀតណាមដែលដឹកបន្លែ ផ្លែឈើ ត្រី សាច់ ទំនិញប្រើប្រាស់ប្រចាំថ្ងៃពីប្រទេសវៀតណាមមកប្រទេសកម្ពុជាតាមម៉ូតូ និងដឹកត្រឡប់ទៅវិញនូវស្វាយកម្ពុជា និងផ្លែឈើផ្សេងៗទៀត។

អ្នកលក់ដុំរកប្រាក់ចំណេញបានច្រើនពីបណ្តាញចែកចាយផ្លែស្វាយព្រោះពួកគេទិញជាកន្ត្រកពីកម្ពុជា ហើយបែងចែក វេចខ្ចប់និងបិតស្លាកលើផលិតផលរួចលក់បន្ត។ ដូច្នេះហើយ ទើបពួកគេលក់បានក្នុងតម្លៃខ្ពស់។

**(៤) ឈ្មួញ ឬអ្នកលក់រាយជនជាតិវៀតណាម**

ឈ្មួញ ឬអ្នកលក់រាយជនជាតិវៀតណាមនៅក្នុងផ្សារទិញផ្លែស្វាយពីអ្នកលក់ដុំហើយលក់បន្តឱ្យអតិថិជន។ ទីតាំងរកស៊ីរបស់ពួកគេគឺស្ថិតនៅឆ្ងាយពីព្រំដែនប្រមាណពី ៦០ ទៅ២០០គីឡូម៉ែត្រ ហើយពួកគេធ្វើដំណើរទៅតំបន់ព្រំដែនមិនត្រឹមតែដើម្បីទិញផ្លែស្វាយប៉ុណ្ណោះទេ ថែមទាំងទិញកសិផលផ្សេងៗទៀតដែលដាំដុះនៅប្រទេសថៃ ដូចជា អំពិល ធុរេន ឡុងកុងជាដើម។

## ២.៣.៣ បន្លែ

### ក. តម្លៃបន្លែដែលពេញនិយម

ការសិក្សាស្រាវជ្រាវបានរកឃើញថា ជារៀងរាល់ថ្ងៃប្រទេសកម្ពុជានាំចូលនូវបន្លែយ៉ាងច្រើនដូចជាត្រសក់ ឪឡឹក ប៉េងប៉ោះ ម្ទេស ស្ពៃក្តោប ម្ទេសប្លោក ផ្លែស្ពៃ រំដេង ការ៉ុត ននោង ម្រះ ឃ្លោក ពោតខ្ចី ស្លឹកខ្ទឹម ខ្ទឹមក្រហម ស្ពៃតឿ ផ្លែអង្ក្រា ត្រប់វែង ពោត ស្មៀតពោត ។ល។ យើងពិតជាភ្ញាក់ផ្អើលណាស់ដែលប្រទេសកម្ពុជានាំចូលបន្លែជាច្រើនមុខបែបនេះ ព្រោះបន្លែទាំងនេះងាយស្រួលដាំនៅក្នុងប្រទេសកម្ពុជា ដូចជា ពោត ស្លឹកគ្រៃ រំដេង ឪឡឹក ត្រសក់ ។ល។

ការស្រាវជ្រាវប្រឈមនឹងឧបសគ្គខ្លះៗក្នុងការប្រមូល និងប្រៀបធៀបតម្លៃរបស់បន្លែព្រោះទីផ្សារបន្លែមានការបត់បែនខ្លាំង។

យើងបានរកឃើញថា បន្លែរបស់ប្រទេសវៀតណាមលក់នៅកម្ពុជាមានតម្លៃថ្លៃ។ កសិករដាំបន្លែជនជាតិវៀតណាមលក់បន្លែក្នុងតម្លៃថោក ប៉ុន្តែអ្នកប្រើប្រាស់ជនជាតិកម្ពុជាទិញក្នុងតម្លៃថ្លៃ។ ទោះជាយ៉ាងណាក៏ដោយ តម្លៃថ្លៃគឺដោយសារការបូកបន្ថែមនូវតម្លៃដឹកជញ្ជូន ថ្លៃពលកម្ម ថ្លៃឆ្លងកាត់ព្រំដែន និងការខូចខាតបន្លែ។

តារាងទី៤៖ តម្លៃបន្លែពេញនិយមដែលនាំចេញពីវៀតណាមមកកម្ពុជា

| បន្លែ | ឯកតា | (១) | (២) | (៣) | (៤) | (៥) | (៦) |
|---|---|---|---|---|---|---|---|
| ត្រសក់ | ដុង/គក | ២.៥០០ | ៣.០០០ | ៤.៥០០ | ៧.០០០ | ១០.០០០ | ១២.៥០០ |
| | រៀល/គក | ៥០០ | ៦០០ | ៩០០ | ១.៤០០ | ២.០០០ | ២.៥០០ |
| ម្ទេស | ដុង/គក | ១៧.០០០ | ១៩.០០០ | ២២.០០០ | ២៩.០០០ | ៣៣.០០០ | ៣៨.០០០ |
| | រៀល/គក | ៣.៤០០ | ៣.៨០០ | ៤.៤០០ | ៥.៨០០ | ៦.៦០០ | ៧.៦០០ |
| ស្ពៃក្តោប | ដុង/គក | ២.៨០០ | ៣.៥០០ | ៤.៥០០ | ៦.០០០ | ៧.៥០០ | ៨.៥០០ |
| | រៀល/គក | ៥៦០ | ៧០០ | ៩០០ | ១.២០០ | ១.៥០០ | ១.៧០០ |
| ប៉េងប៉ោះ | ដុង/គក | ៣.៥០០ | ៤.៥០០ | ៥.៥០០ | ៨.០០០ | ១០.៥០០ | ១៤.០០០ |
| | រៀល/គក | ៧០០ | ៩០០ | ១.១០០ | ១.៦០០ | ២.១០០ | ២.៨០០ |
| ឪឡឹក | ដុង/គក | ២.០០០ | ៣.៥០០ | ៥.០០០ | ៧.០០០ | ៨.០០០ | ៩.០០០ |
| | រៀល/គក | ៤០០ | ៧០០ | ១.០០០ | ១.៤០០ | ១.៦០០ | ១.៨០០ |

ប្រភព៖ ការស្ទង់មតិក្នុងខែមករា

សម្គាល់

(១)កសិករវៀតណាម

(២) ទីផ្សារលក់បន្លែបោះដុំ

(៣) តំបន់ដឹកបន្លែឆ្លងកាត់ (ទឹកដីវៀតណាម)

(៤) តំបន់ទទួលបន្លែ (ទឹកដីកម្ពុជា)

(៥) ទីផ្សារលក់បន្លែធំនៅភ្នំពេញ/ខេត្ត

(៦) អ្នកប្រើប្រាស់ចុងក្រោយ/អតិថិជនខ្មែរ

## ខ. បណ្តាញចែកចាយបន្លែពីវៀតណាមទៅកម្ពុជា

### (១) កសិករដាំបន្លែជនជាតិវៀតណាមនៅតំបន់ដីសណ្តទន្លេមេគង្គ

ការសិក្សាស្រាវជ្រាវបានរកឃើញថា បន្លែជិត ៩០% ដែលនាំចេញទៅប្រទេសកម្ពុជាគឺដាំនៅខេត្តនានានៅតំបន់ដីសណ្តទន្លេមេគង្គ ជិតប្រទេសកម្ពុជាដូចជា ខេត្តអានយ៉ាង (មានចំងាយ ១០-៤០ គីឡូម៉ែត្រពីព្រំប្រទល់ខេត្តតាកែវ) ខេត្តកាន់ថូ (មានចំងាយ ៦០ គីឡូម៉ែត្រ ពីព្រំប្រទល់ខេត្តតាកែវ) ខេត្តដុងថាប់ (មានចំងាយ ៥០គីឡូម៉ែត្រ ពីព្រំប្រទល់ខេត្តស្វាយរៀង) ខេត្តឡុងអាន (មានចំងាយ ២០-៤០គីឡូម៉ែត្រ ពីព្រំទល់ខេត្តស្វាយរៀង)។ បន្លែ ១០% ផ្សេងទៀតដាំនៅទីក្រុងដាឡាត់ (បន្លែមានគុណភាពខ្ពស់ និងមានឈ្មោះល្បីដាំដុះប្រទេសវៀតណាម) និងប្រភេទបន្លែមកពីចិនដូចជាការ៉ុត និងប៉េងប៉ោះ។

ដ្យាក្រាមទី៣៖ បណ្តាញចែកចាយបន្លែពីវៀតណាមមកកម្ពុជា



### (២) ទីផ្សារលក់ដុំបន្លែ

មានទីផ្សារលក់ដុំបន្លែជាច្រើនកន្លែងនៅតំបន់ដីសណ្តដែលប្រជាជនធ្វើការជួញដូរបន្លែជាច្រើនប្រភេទ។



រូបភាពទី៦៖ បន្លែជញ្ជូនពីទីផ្សារលក់ដុំទៅតំបន់ឆ្លងកាត់នៅព្រំដែនដោយរថយន្តដឹកទំនិញ

+ ទីផ្សារលក់បន្លែបោះដុំនៅចូដុក[11] គឺជាទីតាំងចម្បងដែលនាំបន្លែទៅកាន់ប្រទេសកម្ពុជា តាមខេត្តតាកែវ។
+ ទីផ្សារលក់បន្លែបោះដុំនៅហុងង្វ[12] ជាទីតាំងចម្បងដែលនាំបន្លែទៅកាន់ប្រទេសកម្ពុជាតាមខេត្តស្វាយរៀង និងព្រៃវែង។



រូបភាពទី៧៖ បន្លែដឹកជញ្ជូនឆ្លងកាត់បន្ទាត់ព្រំដែនដោយម៉ូតូ

- ម្ចាស់ជំនួញខ្មែរ ឬសាច់ញាតិរបស់ពួកគេជាច្រើនទៅផ្សារចូដុក និងហុងង្វ ដើម្បីជ្រើសរើសនិងទិញបន្លែជារៀងរាល់ថ្ងៃ។ បន្ទាប់មក ពួកគេដឹកជញ្ជូនបន្លែដោយរថយន្តដឹកទំនិញ ឬរថយន្តទូរីសទៅកាន់តំបន់ឆ្លងកាត់ (៣) នៅតាមព្រំដែន ហើយជួលអ្នកនៅតំបន់នោះដឹកជញ្ជូនបន្លែឆ្លងកាត់ព្រំដែន។

### (៣) តំបន់ដឹកបន្លែឆ្លងកាត់

តំបន់ដឹកបន្លែឆ្លងកាត់គឺជាកន្លែងដែលឈ្មួញខ្មែរជួលកម្មករក្នុងស្រុកដើម្បីនាំបន្លែឆ្លងកាត់ព្រំដែន ព្រោះពលរដ្ឋក្នុងស្រុកអាចនាំទំនិញចូលរួចពន្ធ បើទំនិញនោះមានតម្លៃទាបជាង ២ លានដុង (ប្រហែល ៤០០.០០០រៀល)។ ដូច្នេះឈ្មួញខ្មែរចតឡានធំមួយនៅដីខ្មែរហើយជួលកម្មករនៅតំបន់នោះ

[11] ក្រុង Chau Doc នៅខេត្តអានយ៉ាង មានចម្ងាយ១៦គីឡូម៉ែត្រពីច្រកព្រំដែនអន្តរជាតិភ្នំដិន ខេត្តតាកែវ។

[12] ក្រុង Hong Ngu នៅខេត្ត Dong Thap មានចម្ងាយ៤០គីឡូម៉ែត្រពីខេត្តស្វាយរៀង ១គីឡូម៉ែត្រពីខេត្តកណ្តាល និង១៧គីឡូម៉ែត្រពីខេត្តព្រៃវែង។

ដឹកជញ្ជូនបន្លែពីទឹកដីនៃប្រទេសវៀតណាមមកទឹកដី នៃប្រទេសកម្ពុជា ដោយមិនបាច់បង់ពន្ធទាំងខាងវៀតណាម និងខាងកម្ពុជា។

ឈ្មួញខ្មែរភាគច្រើនមិនបានទៅប្រទេសវៀតណាមទេ ពួកគេបញ្ជាទិញបន្លែពីឈ្មួញជនជាតិវៀតណាមដោយផ្ទាល់។ ដូច្នេះហើយ តំបន់ដឹកបន្លែឆ្លងកាត់គឺជាកន្លែងដែលឈ្មួញវៀតណាមជួលប្រជាពលរដ្ឋក្នុងស្រុក ដើម្បីបញ្ជូនបន្លែមកទឹកដីកម្ពុជា។

**(៤) តំបន់ទទួលបន្លែ**

វាជាកន្លែងដែលមានរថយន្តផ្ទុកលើសទម្ងន់[13] ជាច្រើនចតដើម្បីចាំទទួលបន្លែ និងផលិតផលវៀតណាមផ្សេងទៀត រួចដឹកជញ្ជូនមកភ្នំពេញ។ ជាទូទៅវាស្ថិតនៅលើទឹកដីកម្ពុជា ហើយនៅជិតព្រំដែន។

**(៥) ទីផ្សារបន្លែធំ (នៅកម្ពុជា)**

វាជាកន្លែងដែលនៅជិតទីក្រុងភ្នំពេញ និងជាកន្លែងដែលឈ្មួញប្រមូលទិញបន្លែ ផលិតផលក្នុងស្រុក និងផលិតផលកសិកម្មវៀតណាមជាច្រើនប្រភេទ។ បន្ទាប់មក ឈ្មួញធ្វើការចែកចាយបន្លែទាំងនោះទៅកាន់ទីផ្សារក្នុងរាជធានីភ្នំពេញ និងខេត្តនានា។

មានកន្លែងលក់បន្លែមួយកន្លែងនៅក្នុងទីក្រុងភ្នំពេញដែលចែកចាយបន្លែទៅកាន់ផ្សារនានាជុំវិញភ្នំពេញ និងមានមួយកន្លែងទៀតដែលមានចម្ងាយ ១១ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញដែលជាកន្លែងចែកចាយបន្លែទៅកាន់ខេត្តនានាក្នុងប្រទេសកម្ពុជា។

[13] ចំណុះនៃរថយន្តដែលបានកំណត់គឺស្មើនឹង១៦តោន ប៉ុន្តែឈ្មួញខ្មែរកែច្នៃរថយន្តឱ្យមានទំហំលើសហើយអាចផ្ទុកស្រូវពី៣០ទៅ៥៥តោន ឬផ្ទុកបន្លែ ផ្លែឈើពី១០-១៥តោន។

## ២.៣.៤ ជី និងថ្នាំកម្ចាត់សត្វល្អិត

### ក. តម្លៃជី និងថ្នាំកម្ចាត់សត្វល្អិត

លទ្ធផលនៃការស្ទង់មតិបង្ហាញថាទីផ្សារជី និងថ្នាំកម្ចាត់សត្វល្អិតគឺមានភាពស្មុគស្មាញណាស់ វាត្រូវបានជួញដូរដោយភ្នាក់ងារឈ្មួញកណ្តាលជាច្រើននាក់ ហើយមិនមានព័ត៌មានច្បាស់លាស់ទេមុនពេលលក់ឱ្យកសិករខ្មែរ។ គុណវិបត្តិជាច្រើនធ្លាក់លើកសិករខ្មែរ ព្រោះពួកគាត់ពឹងផ្អែកទាំងស្រុងលើព័ត៌មានដែលទទួលបានពីអ្នកលក់ទំនិញ។

ឧទាហរណ៍៖ ជីអ៊ុយរ៉េដែលលក់មកឱ្យកម្ពុជាគឺជាជីដែលផលិតនៅអាមេរិក ចិន ហ្វីលីពីន និងរោងចក្រផលិតជី ៣ កន្លែងផ្សេងទៀត នៅប្រទេសវៀតណាម រួមមាន Đầu Trâu (ជីសញ្ញាក្បាលក្របី) Đạm Phú Mỹ (Phu My UREA) និង Việt Nhật (ជីវៀតណាម-ជប៉ុន)។ ជីដែលមកពីប្រភពដើមខុសគ្នាគឺមានគុណភាព និងតម្លៃខុសគ្នា វាមានតម្លៃចាប់ពី ៧០.០០០ - ១២០.០០០ ដុងក្នុងមួយបាវ ដែលមានទម្ងន់ ៥០ គីឡូក្រាម (តម្លៃប្រហែល ២៨០ - ៤៨០រៀល/គីឡូក្រាម)។ កសិករខ្មែរមិនស្គាល់ពីប្រភពដើមរបស់ជីទេ ដូច្នេះកសិករខ្មែរមិនអាចប្រៀបធៀបតម្លៃនិងគុណភាពជីបានឡើយ។

ឧទាហរណ៍៖ ថ្នាំកម្ចាត់សត្វល្អិត/ថ្នាំគីមីការពាររុក្ខជាតិប្រភេទដូចគ្នាមានកញ្ចប់និងមានប្រសិទ្ធភាពដូចគ្នា ប៉ុន្តែភាគរយនៃជាតិគីមីក្នុងមួយកញ្ចប់មានភាពខុសគ្នា ហើយតម្លៃក៏ខុសគ្នាដែរ។ ទោះជាយ៉ាងណាក៏ដោយ កសិករខ្មែរមិនអាចដឹងបានទេព្រោះនៅលើកញ្ចប់សរសេរជាភាសាវៀតណាម ហើយកសិករខ្មែរពឹងផ្អែកលើព័ត៌មានដែលទទួលបានពីអ្នកលក់ជនជាតិខ្មែរ។

តារាងទី៥ បង្ហាញពីតម្លៃជីដែលកសិករខ្មែរនិងវៀតណាមពេញនិយមប្រើ ហើយការសិក្សាអាចធ្វើតាមប្រភេទផលិតផលដែលនាំចូលពីប្រទេសវៀតណាមមកកម្ពុជា ។ ប្រភេទជីនិងថ្នាំកម្ចាត់សត្វល្អិតផ្សេងទៀតមិនអាចសិក្សាពីតម្លៃរបស់វាបានទេដោយសារព័ត៌មានដែលទទួលបានពីឈ្មួញនៅតាមតំបន់ព្រំដែលមានភាពមិនត្រឹមត្រូវ។

តារាងទី៥៖ តម្លៃជីដែលគេនិយមប្រើនៅវៀតណាមនិងកម្ពុជា

| | ឯកតា | (១) | (២) | (៣) | (៤) | (៥) |
|---|---|---|---|---|---|---|
| NPK 20-20-15 (សញ្ញាក្បាលក្របី) | ដុង/បាវ | ៤៧០.០០០ | ៤៩៥.០០០ | ៥៥០.០០០ | ៦៥០.០០០ | ៨០០.០០០ |
| ឬ NPK Bình Điền-Đầu Trâu | រៀល/បាវ | ៩៤.០០០ | ៩៩.០០០ | ១១០.០០០ | ១៣០.០០០ | ១៦០.០០០ |
| អ៊ុយរ៉េ (Phú Mỹ-Vietnam) | ដុង/បាវ | ៣៦៦.០០០ | ៣៧៥.០០០ | ៣៨៥.០០០ | ៤០០.០០០ | ៤៨០.០០០ |
| | រៀល/បាវ | ៧៣.២០០ | ៧៥.០០០ | ៧៧.០០០ | ៨០.០០០ | ៩៦.០០០ |
| កាលី ៣០% | ដុង/បាវ | ៥៨០.០០០ | ៦១០.០០០ | ៦៦០.០០០ | ៧០០.០០០ | ៧៩០.០០០ |
| | រៀល/បាវ | ១១៦.០០០ | ១២២.០០០ | ១៣២.០០០ | ១៤០.០០០ | ១៥៨.០០០ |

ប្រភព៖ ការស្ទង់មតិនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៥

សម្គាល់៖ ជី១បាវមានទម្ងន់សុទ្ធ ៥០គក

(១) រោងចក្រនៅវៀតណាម

(២) ភ្នាក់ងារចែកចាយកម្រិត ១

(៣) ភ្នាក់ងារចែកចាយកម្រិត ២

(៤) កសិករនៅវៀតណាម (តំបន់ព្រំដែន)

(៥) កសិករនៅតាកែវ និងស្វាយរៀង

យោងតាមតារាងទី៥ ប្រភេទជីសុទ្ធ ដូចជា ជីអ៊ុយរ៉េ (នីត្រូសែន) និងជីកាលី មានតម្លៃសមរម្យ កសិករទិញជីមួយបាវក្នុងតម្លៃថេរ។ ផ្ទុយទៅវិញប្រភេទជីចំរុះ ដូចជា ជី NPK 20-20-15 មានតម្លៃថ្លៃ កសិករត្រូវចំណាយប្រាក់ច្រើនក្នុងការទិញជីមួយបាវ។

ការសិក្សាបានបង្ហាញថា ភាគច្រើននៃកសិករវៀតណាមប្រើប្រាស់ជីសុទ្ធ ពីព្រោះវាមានតម្លៃថោក ហើយតម្រូវឱ្យកសិករធ្វើស្រែតាមលក្ខណៈបច្ចេកទេសខ្ពស់។ ផ្ទុយទៅវិញ កសិករខ្មែរចូលចិត្តប្រើជីចំរុះពីព្រោះវាមានភាពងាយស្រួល កសិករខ្មែរមិនចាំបាច់លាយជាមួយជីផ្សេងៗទៀតមុនពេលប្រើប្រាស់វា។ ប៉ុន្តែកសិករខ្មែរត្រូវចំណាយប្រាក់ច្រើនក្នុងការទិញជីមួយបាវ។

ដ្យាក្រាមទី៥៖ បណ្តាញចែកចាយជី និងថ្នាំកម្ចាត់សត្វល្អិតពីវៀតណាមទៅកម្ពុជា




## (១) ក្រុមហ៊ុនផលិតជី និងថ្នាំកម្ចាត់សត្វល្អិត

រូបភាពទី៨៖ រូបសញ្ញាក្រុមហ៊ុនផលិតជី Bình Điền

ប្រទេសវៀតណាមផលិតជីមិនបានគ្រប់គ្រាន់ទេសម្រាប់កសិករវៀតណាមនិងនាំចេញទៅប្រទេសឡាវ និង កម្ពុជា[14] ។ ជីដែលល្បីឈ្មោះជាងគេនៅប្រទេសវៀតណាម និងកម្ពុជាគឺជាជីរបស់ក្រុមហ៊ុន "ប៊ិញដៀន Bình Điền" ដែលមានរូបសញ្ញាក្បាលក្របីលើសម្បកបាវ។ ក្រុមហ៊ុនផលិតជីប៊ិញដៀនផលិតជីសុទ្ធនិងជីចំរុះជាច្រើនប្រភេទ ក្រុមហ៊ុននេះមានភ្នាក់ងារចែកចាយជាច្រើននៅក្នុងប្រទេសកម្ពុជានិងឡាវដោយមានសញ្ញាសំគាល់រូបក្បាលក្របី។

ក្រុមហ៊ុនផលិតជី និងថ្នាំកម្ចាត់សត្វល្អិតមិនលក់ផលិតផលទៅដល់កសិករដោយផ្ទាល់ទេ។ តាមធម្មតា ពួកគេលក់ផលិតផលទៅឱ្យភ្នាក់ងារចែកចាយកម្រិត១ ហើយភ្នាក់ងារចែកចាយកម្រិត១ ភាគច្រើនលក់ផលិតផលបន្តទៅឱ្យភ្នាក់ងារចែកចាយកម្រិត២ក្នុងតម្លៃដូចក្រុមហ៊ុនដែរ ដោយទទួលបានកម្រៃជើងសាពី ៥% ទៅ ៧%។




រូបភាពទី៩៖ ជី NPK 20-20-15 ពីក្រុមហ៊ុនជី Binh Dien លក់ទៅកម្ពុជា

[14] វៀតណាមនាំចេញជី៥៥៣.០០០តោនអំឡុងឆមាសទី១នៃឆ្នាំ២០១៤ ដែលក្នុងនោះជី២១៥.០០០តោនបាននាំចេញទៅកាន់ទីផ្សារកម្ពុជាក្នុងតម្លៃជាង៨០លានដុល្លារអាមេរិក។ ប្រភព៖ http://agro.gov.vn/news/tID23879_Phan-bon-tru-vung-thi-truong-Campuchia.htm

ជីដែលលក់ដាច់បំផុតទៅប្រទេសកម្ពុជាគឺជី NPK 20-20-15 ដែលផលិតដោយជីជាច្រើនប្រភេទលាយគ្នា ហើយជី NPK 20-20-15 របស់ក្រុមហ៊ុនផលិតជីប៊ិញដៀន គឺជាជីដែលពេញនិយមបំផុតនៅកម្ពុជាដោយសារយុទ្ធសាស្ត្រទីផ្សាររបស់ក្រុមហ៊ុននេះ។ ក្រុមហ៊ុនមិនដែលលក់ផលិតផលទៅភ្នាក់ងារចែកចាយកម្រិត ២ និងកសិករដោយផ្ទាល់នោះទេ ដោយសារបរិមាណបញ្ជាទិញតិចតួចពេក។

ក្រុមហ៊ុនលក់ថ្នាំការពាររុក្ខជាតិ និងថ្នាំកម្ចាត់សត្វល្អិតវៀតណាមជាច្រើនបានបើកអាជីវកម្មនៅក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមក្រុមហ៊ុនទាំងនេះ ក្រុមហ៊ុនលក់ថ្នាំការពាររុក្ខជាតិអានយ៉ាង (AGPPS) ជាក្រុមហ៊ុនលក់ផលិតផលថ្នាំកម្ចាត់សត្វល្អិតធំបំផុតក្នុងប្រទេសវៀតណាម ក្រុមហ៊ុននេះមានសាខាជាច្រើននៅកម្ពុជា ហើយមានបុគ្គលិកខ្មែរចុះណែនាំផ្ទាល់ដល់កសិករនៅតាមកសិដ្ឋាន។ យុទ្ធសាស្ត្រនេះទទួលបានជោគជ័យនៅក្នុងប្រទេសវៀតណាម ហើយក្រុមហ៊ុន អាន យ៉ាង បានអនុវត្តតាមយុទ្ធសាស្ត្រគំរូនេះនៅក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។

រូបភាពទី១០៖ រូបសញ្ញា AGPPS

### (២) ភ្នាក់ងារចែកចាយជីនិងថ្នាំសម្លាប់សត្វល្អិតកម្រិត១

ភ្នាក់ងារទាំងនេះគឺជាជនជាតិវៀតណាមនិងខ្មែរ ពួកគាត់ទទួលផលិតផលពីក្រុមហ៊ុន។ បន្ទាប់មក ពួកគាត់លក់ទៅឱ្យភ្នាក់ងារចែកចាយកម្រិត២ក្នុងតម្លៃដូចក្រុមហ៊ុនដែរដោយទទួលបានកម្រៃជើងសាពីក្រុមហ៊ុន។ ការទទួលខុសត្រូវរបស់ពួកគាត់គឺទិញជី និងថ្នាំកម្ចាត់សត្វល្អិតស្តុក រួចហើយចែកចាយបន្តទៅភ្នាក់ងារចែកចាយកម្រិត២ និងប្រមូលប្រាក់ពីភ្នាក់ងារចែកចាយកម្រិត២ ដើម្បីទូទាត់ទៅឱ្យក្រុមហ៊ុន ។ ហានិភ័យខ្លាំងបំផុតសម្រាប់ពួកគាត់គឺក្នុងករណីដែលភ្នាក់ងារចែកចាយកម្រិត២មិនសងប្រាក់ ភ្នាក់ងារចែកចាយកម្រិត១ជាអ្នករ៉ាប់រងចំពោះសំណងនេះជាមួយក្រុមហ៊ុន។

ក្រុមហ៊ុនផលិតជីនិងថ្នាំកម្ចាត់សត្វល្អិតតាមធម្មតាបង្កើតភ្នាក់ងារចែកចាយកម្រិត១ ពី២ ទៅ ៣កន្លែងនៅតាមបណ្តាខេត្តនានា។ យ៉ាងណាមិញ ជីនិងថ្នាំកម្ចាត់សត្វល្អិតជាច្រើនលក់ទៅប្រទេសកម្ពុជាតាមរយៈដៃគូរកស៊ីជនជាតិខ្មែរដ៏ទៃទៀត

ពីព្រោះពួកគេខ្លាចមានភាពមិនយុត្តិធម៌ក្នុងការរកស៊ី ហើយត្រូវការបង់ប្រាក់ច្រើននៅពេលដឹកជញ្ជូនទំនិញក្នុងប្រទេសកម្ពុជា។

**(៣) ភ្នាក់ងារចែកចាយកម្រិត២**

ភ្នាក់ងារទាំងនេះគឺជាឈ្មួញដែលមានតូបលក់ដូរនៅតាមស្រុកនិងភូមិ។ ពួកគេទិញជីនិងថ្នាំកម្ចាត់សត្វល្អិតពីភ្នាក់ងារចែកចាយកម្រិត១ ហើយលក់បន្តទៅឱ្យកសិករ។ ពួកគេភាគច្រើនជាមន្ត្រីរាជការនៅកម្ពុជា ឬជាអ្នកមានទ្រព្យធនច្រើននៅក្នុងសហគមន៍។

តាមធម្មតា ពួកគេទិញជី និងថ្នាំកម្ចាត់សត្វល្អិតជាច្រើនប្រភេទពីក្រុមហ៊ុនផ្សេងៗពីព្រោះកសិករមានតម្រូវការខុសៗគ្នា។

ពួកគេលក់ផលិតផលទៅឱ្យកសិករដោយប្រើប្រាស់លុយសុទ្ធ ឬលក់បណ្តាក់ជាមួយអត្រាការប្រាក់៣% ហើយទូទាត់សងបន្ទាប់ពីប្រមូលផលរួច។

ពួកគេដើរតួជាអ្នកណែនាំកសិករពីរបៀបប្រើប្រាស់ផលិតផល កសិករខ្មែរភាគច្រើនពឹងផ្អែកលើការណែនាំរបស់ភ្នាក់ងារចែកចាយកម្រិត២ ។ តាមធម្មតាពួកគេណែនាំដល់កសិករខ្មែរពីជីចំរុះ NPK 20-20-15 ព្រោះកសិករងាយស្រួលប្រើប្រាស់វា ប៉ុន្តែក្រុមហ៊ុនផលិតជីទទួលបានចំណេញច្រើន។

**(៤) កសិករវៀតណាមនិងខ្មែរ**

ការសិក្សាមិនអាចរកឃើញភ្នាក់ងារចែកចាយជាក់លាក់នៅក្នុងបណ្តាញទីផ្សារលក់ផលិតជី និងថ្នាំកម្ចាត់សត្វល្អិតនៅក្នុងប្រទេសកម្ពុជាទេ ដោយសារមិនមានតម្រុយច្បាស់លាស់ ហើយព័ត៌មានដែលទទួលបាននៅតាមព្រំដែនមិនអាចយកជាការបាន។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាបង្ហាញថាចង្វាក់ទីផ្សារលក់ជី និងថ្នាំសម្លាប់សត្វល្អិតនៅក្នុងប្រទេសកម្ពុជាគឺមានភាពវែងជាងចង្វាក់ទីផ្សារក្នុងប្រទេសវៀតណាម ហើយកសិករខ្មែរចំណាយប្រាក់ច្រើនជាងកសិករវៀតណាមសម្រាប់ផលិតផលដូចគ្នា បើតាមការប្រៀបធៀបតម្លៃនៅក្នុងប្រទេសកម្ពុជា និងវៀតណាម។

ការសិក្សាបានបង្ហាញឱ្យដឹងថា កសិករនៅខេត្តតាកែវប្រើប្រាស់ជីនិងថ្នាំកម្ចាត់សត្វល្អិតច្រើនជាងកសិករក្នុងខេត្តស្វាយរៀង។ ភ្នាក់ងារចែកចាយជាច្រើនបាននិយាយថាខេត្តតាកែវមានផ្ទៃដីធ្វើស្រែ IR504 ធំជាងខេត្តស្វាយរៀង។

## ៣. សន្និដ្ឋាន និងអនុសាសន៍

### ៣.១ ស្រូវ

### ក. សន្និដ្ឋាន

- ប្រទេសកម្ពុជាបានលក់ស្រូវស្រាល (IR504) និងស្រូវធ្ងន់ (ម្លិះ, Sóc) យ៉ាងច្រើនទៅប្រទេសវៀតណាម។ ប្រទេសវៀតណាមទិញស្រូវស្រាលយកមកកែច្នៃរួចនាំចេញទៅលក់តាមទីផ្សារតូចៗ ចំណែកស្រូវធ្ងន់ (ម្លិះ) ប្រើសម្រាប់ទីផ្សារក្នុងប្រទេសវៀតណាម។ ទិន្នផលស្រូវរបស់ខេត្តតាកែវដែលបានលក់ទៅប្រទេសវៀតណាមមានចំនួនច្រើនជាងទិន្នផលស្រូវរបស់ខេត្តស្វាយរៀងដែលបានលក់ទៅឱ្យប្រទេសវៀតណាម។
- ការចែកចាយអង្ករពីប្រទេសកម្ពុជាទៅវៀតណាមមានលក្ខណៈជាក់លាក់ ការចែកចាយនេះ គឺសម្រាប់តែអ្នកដែលមានសាច់ញាតិជិតស្និទ្ធជាមួយរដ្ឋាភិបាលកម្ពុជាតែប៉ុណ្ណោះ។ ដូច្នេះហើយ វាមានការលំបាកយ៉ាងខ្លាំងចំពោះសហគមន៍កសិកម្មក្នុងការចូលរួមលើបណ្តាញទីផ្សារជួញដូរស្រូវនេះ។

បើទោះជាសហគមន៍កសិកម្មទទួលបាននូវការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ទីកន្លែង និងជំនាញក្នុងការប្រកបអាជីវកម្មក៏ដោយ ក៏យើងមិនប្រាកដថាសហគមន៍កសិកម្មអាចទទួលជោគជ័យក្នុងការប្រកបមុខរបរជួញដូរស្រូវនោះទេ។

### ខ. អនុសាសន៍

- សហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជាគួរយកចិត្តទុកដាក់លើការដាំដុះស្រូវធ្ងន់ (ប្រភេទស្រូវម្លិះ និងស្រូវ Soc) ដើម្បីផ្គត់ផ្គង់ទៅទីផ្សារក្នុងប្រទេសវៀតណាមពីព្រោះអ្នកប្រើប្រាស់ជនជាតិវៀតណាមមានតម្រូវការស្រូវធ្ងន់ច្រើន។ លើសពីនេះ ហេដ្ឋារចនាសម្ព័ន្ធកសិកម្មនៅក្នុងប្រទេសវៀតណាមប្រើសម្រាប់តែការដាំដុះស្រូវស្រាលទេ ហើយប្រទេសវៀតណាមពិបាកដាំដុះស្រូវធ្ងន់ដូចដែលជនជាតិវៀតណាមធ្លាប់បានដាំដុះពីមុនមកណាស់។ នេះជាមូលហេតុដែលសហគមន៍កសិកម្មកម្ពុជា គួរយកចិត្តទុកដាក់ខ្ពស់ទៅ

លើការដាំដុះស្រូវធ្ងន់ដែលជាស្រូវមានគុណភាពខ្ពស់ស្របតាមលក្ខណៈស្តង់ដារស្រូវស្អាត ស្រូវសរីរាង្គ និងស្រូវល្អ។

- សម្រាប់យុទ្ធសាស្ត្រប្រកបដោយនិរន្តរភាព ប្រទេសកម្ពុជាត្រូវវិនិយោគប្រព័ន្ធម៉ាស៊ីនកិនស្រូវសម្រាប់កែច្នៃស្រូវទៅជាអង្ករសម្រូប ហើយលក់អង្ករសម្រូបនេះទៅប្រទេសវៀតណាមជំនួសឱ្យការលក់ស្រូវ។ ប្រព័ន្ធម៉ាស៊ីនកិនស្រូវសម្រាប់កែច្នៃអង្ករសម្រូបនេះមិនសូវចំណាយដើមទុនច្រើនទេ ហើយក៏មិនតម្រូវឱ្យមានជំនាញខ្ពស់ក្នុងការប្រើប្រាស់វាដែរ។ សហគមន៍កសិកម្មអាចប្រើប្រាស់អង្កាមសម្រាប់ដុត[15] ហើយលក់ទៅប្រទេសវៀតណាមក្នុងតម្លៃខ្ពស់។ លើសពីនេះ វៀតណាមមានរោងម៉ាស៊ីនកិនស្រូវជាលក្ខណៈឯកជនច្រើននៅជិតព្រំដែនកម្ពុជា ចម្ងាយប្រហែលពី ១០ ទៅ ២០គីឡូម៉ែត្រពីព្រំដែន។
- ការលក់ស្រូវ IR504 ទៅវៀតណាមមិនមែនជាយុទ្ធសាស្ត្រប្រកបដោយនិរន្តរភាពទេ ដូច្នេះ កម្ពុជាគួរបង្កើនសមត្ថភាពកែច្នៃស្រូវសម្រាប់នាំចេញព្រោះវាសមស្របតាមគោលបំណងរបស់រដ្ឋាភិបាលកម្ពុជា ហើយកម្ពុជាមិនគួរបង្កើនផ្ទៃដីធ្វើស្រូវស្រាលដូចជាស្រូវ IR504 ទេ។ មានមូលហេតុជាច្រើនដែលបញ្ជាក់ថា តម្រូវការស្រូវ IR504 នៅវៀតណាមនឹងមានការធ្លាក់ចុះខ្លាំងនៅពេលអនាគតដ៏ខ្លីខាងមុខ ពីព្រោះចិនកាត់បន្ថយ ៥៤% និងប្រទេសនៅតំបន់អាហ្វ្រិកកាត់បន្ថយ ៣០% នៃបរិមាណស្រូវដែលមានគុណភាពអន់ដែលបាននាំចេញដោយវៀតណាម។ នៅពេលបច្ចុប្បន្ននេះ មានហេតុផលច្រើនទាក់ទងនឹងនយោបាយទំនាក់ទំនងជាមួយចិន និងការប្រកួតប្រជែងចំពោះស្រូវដែលមានគុណភាពអន់ដែលបាននាំចេញពីប្រទេសឥណ្ឌា ភូមា។ ការនាំចេញស្រូវស្រាលពីប្រទេសវៀតណាមទៅកាន់ទីផ្សារពិភពលោកនឹងមានការធ្លាក់ចុះ ហើយរដ្ឋាភិបាលវៀតណាមមានគម្រោងកាត់បន្ថយតំបន់ដាំដុះស្រូវ IR504 ដោយការដាំដុះស្រូវធ្ងន់ជំនួសវិញ។

[15] កសិករវៀតណាមបានធ្វើម៉ាស៊ីនសាមញ្ញដើម្បីកែច្នៃអង្កាមទៅជាអុសគឺងាយស្រួលដឹកជញ្ជូនហើយលក់ក្នុងតម្លៃខ្ពស់ ពីព្រោះក្រុមហ៊ុនជាច្រើននិងរោងចក្រថាមពលអគ្គិសនីប្រើអង្កាមសម្រាប់ដុតដែរ

## ៣.២ ស្វាយ

ជនជាតិវៀតណាមចូលចិត្តបរិភោគស្វាយខ្ចីរបស់ប្រទេសកម្ពុជាណាស់ តម្រូវការស្វាយខ្ចីរបស់ប្រទេសកម្ពុជាមានការកើនឡើងចាប់តាំងពីឆ្នាំ២០០០មក។ ប៉ុន្តែការសិក្សានេះព្យាករថា ការនាំស្វាយចេញពីប្រទេសកម្ពុជាទៅវៀតណាមនឹងប្រឈមមុខនឹងបញ្ហាមួយចំនួននាពេលអនាគតដ៏ខ្លីខាងមុខពីព្រោះស្វាយដែលមានគុណភាពដូចគ្នានេះត្រូវបានដាំដុះនៅក្នុងស្រុកជាច្រើនក្នុងប្រទេសវៀតណាមជាប់ព្រំដែនប្រទេសកម្ពុជា។ ក្រៅពីនេះ ពូជស្វាយកម្ពុជាត្រូវបានដាំដុះផងដែរនៅលើផ្ទៃដីដ៏ធំធេងមួយកន្លែងក្នុងតំបន់ដីសណ្តទន្លេមេគង្គ ហើយប្រហែលជាពីរ ឬបីឆ្នាំទៀតពូជស្វាយនេះនឹងផ្តល់ផល។ លើសពីនេះ កសិករវៀតណាមអាចដាំស្វាយបានគ្រប់ពេលក្នុងមួយឆ្នាំ កសិករអាចប៉ាន់ប្រមាណពីពេលវេលាប្រមូលផលដែលអាចលក់បានក្នុងតម្លៃខ្ពស់ និងវិធីថែទាំចម្ការស្វាយ ហើយពួកគាត់អាចប្រមូលផលតាមពេលវេលាដែលបានគ្រោងទុក។

## ៣.៣ សត្វពាហនៈ

កសិករកម្ពុជាភាគច្រើនចិញ្ចឹមសត្វពាហនៈ រួមមានគោនិងក្របីដែលក្នុងមួយគ្រួសារមានគោ ក្របី ពីពីរទៅបីក្បាលប៉ុណ្ណោះ កសិករខ្មែរភាគច្រើនចិញ្ចឹមគោ និងមួយចំនួនតូចចិញ្ចឹមក្របី។ តាមធម្មតា កសិករលក់សត្វពាហនៈទៅឱ្យ "ឈ្មួញកណ្តាលទិញសត្វពាហនៈ" នៅក្នុងសហគមន៍។ គោ ក្របីជាច្រើនក្បាលដែលបានលក់ទៅប្រទេសវៀតណាម ហើយចំនួននេះហាក់ដូចជាកើនឡើងខ្ពស់ក្នុងអំឡុងពេលមួយខែមុនពេលចូលឆ្នាំខ្មែរក្នុងប្រទេសកម្ពុជា[16] ។

តម្លៃរវាងការទិញនិងការលក់សត្វពាហនៈគឺខុសគ្នាឆ្ងាយណាស់ ហើយប្រាក់ចំណេញភាគច្រើនបានទៅឈ្មួយកណ្តាលទិញសត្វពាហនៈជនជាតិខ្មែរ ពីព្រោះពួកគាត់ទិញគោពីប្រទេសកម្ពុជាក្នុងតម្លៃថោក ហើយដាក់លក់ដេញថ្លៃនៅទីផ្សារសត្វពាហនៈនៅក្នុងប្រទេសវៀតណាមក្នុងតម្លៃថ្លៃ។

តម្រូវការសត្វពាហនៈធំៗសម្រាប់យកសាច់ និងសត្វពាហនៈតូចៗសម្រាប់ចិញ្ចឹមនៅក្នុងប្រទេសវៀតណាមមានការកើនឡើងខ្ពស់ ពីព្រោះរដ្ឋាភិបាលវៀតណាមលើកទឹកចិត្តឱ្យមានការបង្កើនចំនួនគោនៅតាមបណ្តាខេត្តជាប់នឹងប្រទេសកម្ពុជា។ ដូច្នេះ ការស្រាវជ្រាវនេះជំរុញឱ្យសហគមន៍កសិកម្មកម្ពុជាបង្កើតសេវាកម្ម "ទីផ្សារសត្វពាហនៈរួមគ្នា" សហគមន៍អាចប្រមូលគោនិងក្របីពីសមាជិកនិងកសិករ រួចដឹកជញ្ជូនទៅទីផ្សារគោក្របីនៅតាមព្រំដែនក្នុងប្រទេសវៀតណាមដើម្បី

[16] ចំនួនគោក្របីមកកាន់ប្រទេសវៀតណាមកើនឡើងយ៉ាងខ្លាំងរៀងរាល់ថ្ងៃពីខែមីនាដល់ពាក់កណ្តាលខែមេសា ក្នុងចំណោមសត្វគោ ភាគច្រើននៃពួកគេជាសត្វគោតូចៗសម្រាប់ចិញ្ចឹម។ ឈ្មួញភាគច្រើននិយាយថា កសិករខ្មែរលក់គោតូចៗ ពីព្រោះពួកគាត់ត្រូវការប្រាក់សម្រាប់ឆ្នាំថ្មី និងថ្ងៃឈប់សម្រាកជាច្រើនក្នុងខែ មីនា និងខែមេសា។

ដាក់លក់ដេញថ្លៃ។ មុខរបរនេះអាចផ្តល់ប្រាក់ចំណេញដល់កសិករខ្មែរផង និងកសិករវៀតណាមផងដែរ។ មុខរបរនេះគឺមានលក្ខណៈសាមញ្ញ ងាយស្រួលនិងផ្តល់ប្រយោជន៍ដល់សមាជិកសហគមន៍។ លើសពីនេះ រដ្ឋាភិបាលវៀតណាមនិងកម្ពុជាគាំទ្រមុខរបរនេះ ដូច្នេះហើយសហគមន៍មិនចាំបាច់ចំណាយប្រាក់ច្រើនទេនៅតំបន់ព្រំដែន។

## ៣.៤ បន្លែ និងផ្លែឈើ

### ក. សន្និដ្ឋាន

កម្ពុជានាំចូលបន្លែនិងផ្លែឈើយ៉ាងច្រើនពីប្រទេសវៀតណាមសម្រាប់បរិភោគប្រចាំថ្ងៃ។ បន្លែ និងផ្លែឈើជាច្រើនបាននាំចូលពីប្រទេសវៀតណាមមកកម្ពុជាតាមផ្លូវគោកក្នុងខេត្តតាកែវ ព្រៃវែង ស្វាយរៀង និងតាមផ្លូវទឹកក្នុងខេត្តកណ្តាល ។

បន្លែនិងផ្លែឈើជាច្រើនដែលលក់មកកម្ពុជាត្រូវបានដាំដុះនៅតំបន់ដីសណ្តទន្លេមេគង្គតាមខេត្តជាប់ព្រំដែនដូចជាខេត្ត អានយ៉ាង ដុងថាប់ ឡុងអាន និង កាន់ថូជាដើម។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាបានរកឃើញថា បន្លែ (ការ៉ុត និងដំឡូងបារាំង) និងផ្លែឈើ (ក្រូច ផ្លែប៉ោម ទំពាំងបាយជូរ) ចិនមួយចំនួនធំលក់មកកម្ពុជាដោយបិទស្លាកជាផលិតផលវៀតណាម។

តម្លៃនៃការទិញ និងលក់បន្លែនិងផ្លែឈើដែលនាំចូលពីប្រទេសវៀតណាមមកកម្ពុជាគឺមានតម្លៃថ្លៃដោយសារការបូកបន្ថែមតម្លៃនៃការដឹកជញ្ជូន និងការខូចខាតបន្លែក្នុងអំឡុងពេលដឹកជញ្ជូន។

### ខ. អនុសាសន៍

សហគមន៍កសិកម្មកម្ពុជា និងអាជ្ញាធរមូលដ្ឋានត្រូវលើកទឹកចិត្ត និងអប់រំកសិករឱ្យគាត់ដាំបន្លែសំខាន់មួយចំនួនសម្រាប់បរិភោគប្រចាំថ្ងៃមានដូចជា ត្រសក់ ប៉េងប៉ោះ ល្ពៅ ម្រះ ស្លឹកខ្ទឹម និងឪឡឹកជាដើម។ ទោះជាយ៉ាងណាក៏ដោយ ការដាំបន្លែត្រូវមានគ្រាប់ពូជ ជំនាញក្នុងការថែទាំ និងទម្លាប់ល្អរបស់កសិករ។ សហគមន៍កសិកម្មត្រូវការជំនួយពីខាងក្រៅក្នុងការជ្រើសរើសគ្រាប់ពូជ និងជំនាញក្នុងការដាំបន្លែពីព្រោះការដាំបន្លែគឺមានភាពខុសគ្នាឆ្ងាយពីការធ្វើស្រែដែលជាទំលាប់របស់កសិករខ្មែរ។

## ៣.៥ ជី និងថ្នាំកម្ចាត់សត្វល្អិត

ទីផ្សារលក់ជីនិងថ្នាំកម្ចាត់សត្វល្អិតនៅតាមព្រំដែនជាប់ប្រទេសកម្ពុជាកន្លងមកមិនមានតម្លាភាពទេ ហាងលក់ជី និងថ្នាំសម្លាត់សត្វល្អិតជាច្រើនជាអ្នកក្តោបក្តាប់និងគ្រប់គ្រងព័ត៌មាន។ កសិករខ្មែរខ្វះខាតព័ត៌មានជាច្រើនទាក់ទងនឹងផលិតផលនេះ។ ហេតុដូច្នេះហើយ ចំពោះផលិតផលដូចគ្នាកសិករខ្មែរទិញថ្លៃជាងកសិករនៅវៀតណាម ។

កសិករខ្មែរភាគច្រើនប្រើប្រាស់ជីចំរុះពីព្រោះវាងាយស្រួលក្នុងការប្រើប្រាស់ ប៉ុន្តែជីនេះមានតម្លៃថ្លៃណាស់ និងជាផលិផលចម្បងក្នុងមុខរបរលក់ជីនៅកម្ពុជា។

តម្រូវការជីនិងថ្នាំកម្ចាត់សត្វល្អិតរបស់កសិករខ្មែរនឹងមានការកើនឡើងពីព្រោះមានខេត្តជាច្រើនក្នុងប្រទេសកម្ពុជាចង់ប្តូរពីការផលិតស្រូវធ្ងន់មកផលិតស្រូវស្រាលដូចជនជាតិវៀតណាមដែរ។

សហាគមន៍កសិកម្មគួរបង្កើតសេវាកម្ម "អាជីវកម្មទិញទំនិញរួមគ្នា" សម្រាប់សមាជិកនិងកសិករ។ សហាគមន៍អាចទិញជីនិងថ្នាំកម្ចាត់សត្វល្អិតដោយផ្ទាល់ពីសាខាលក់ជីនិងថ្នាំកម្ចាត់សត្វល្អិតដែលជាផលិតផលល្អរបស់វៀតណាមក្នុងប្រទេសកម្ពុជាបាន ដូចជា ក្រុមហ៊ុនប៊ិញ ដៀន (ជីសញ្ញាក្បាលក្របី) ថ្នាំការពាររុក្ខជាតិ អានយ៉ាង (ថ្នាំកម្ចាត់សត្វល្អិត AGPPS) ។ ក្រុមហ៊ុនទាំងនេះជាក្រុមហ៊ុនក្នុងប្រទេសវៀតណាមដែលផលិតផលមានគុណភាពល្អ តម្លៃសមរម្យ មានការណែនាំ និងការទទួលខុសត្រូវក្នុងសង្គម ហើយមានសាខាក្នុងប្រទេសកម្ពុជា។ អាជីវកម្មទិញទំនិញរួមគ្នានឹងផ្តល់ប្រយោជន៍ដល់សហាគមន៍កសិកម្ម សមាជិក កសិករ និងចូលរួមចំណែកការពារបរិស្ថានផងដែរ។


របាយការណ៍ដោយ

**បណ្ឌិត ហៃ ត្រាន**

សាកលវិទ្យាល័យ អាន យ៉ាង វៀតណាម


ថ្ងៃទី៦ មីនា ឆ្នាំ២០១៥

**Report survey prices of agricultural products and inputs between Vietnam and Cambodia border**

Printed in September 2015

Published by Department of Agricultural Cooperative Promotion of General Directorate for Agriculture (MAFF)

The project for Establishing Business-oriented Agricultural Cooperative Models (BPAC)

Address: # 54B/49F, St. 395-656, Sangkat Toeuk Laak 3, Khan Toul Kok, Phnom Penh, Cambodia

Phone: (023) 883 427, Fax: (023) 883 427

© The project for Establishing Business-oriented Agricultural Cooperative Models